## ១) ការប្រមូលផល

ដើម្បីប្រមូលផលផ្លែមៀនឱ្យបានត្រឹមត្រូវល្អ យើងគួរពិនិត្យលក្ខណៈសំគាល់មួយចំនួន ដូចខាងក្រោម :

- សំគាល់លក្ខណៈទុំរបស់វា ដោយមានពណ៌រលោងភ្លឺថ្លា
- ប្រភេទមៀនខ្លះមានពណ៌ត្នោតឡើងមេ្យាដូចស៊ីម៉ង់ត៍នៅលើសំបករបស់វា
- មានសាច់ក្រាស់ ហើយគ្រាប់ខ្មៅរលោង
- គេអាចប្រមូលផលដោយប្រើដៃបើផ្លែនៅទាប ឬជង្កៀបឫស្សីចំពោះផ្លែខ្ពស់



- បេះផ្លែនៅពេលដែលស្ងួតទឹកសន្សើម ឬទឹកភ្លៀង ដើម្បីងាយស្រួលក្នុងការប្រមូល និងធ្វើឱ្យផ្លែមិនឆាប់រលួយស្អុយ។ ប្រសិនបើប្រមូលផលមិនអស់ភ្លាមទេ យើងអាចប្រមូលផលពេលថ្ងៃត្រង់ក៏បាន ប៉ុន្តែត្រូវជញ្ជូនវាដាក់ក្នុងម្លប់ភ្លាម។ ពេលវេលាដែលល្អគឺម៉ោង ៨-១០ ព្រឹក និងម៉ោង ៣-៥ រសៀល។

## ២) ការតំរឹម និងសំអាត

- យកផ្លែមៀនចេញពីកន្ត្រក ដោយសង្កត់ក្បាលកន្ត្រក និងហូតចេញថ្នមៗ
- បេះស្លឹកចេញ និងកាត់មែកឱ្យបានត្រឹមស្មើៗគ្នា
- តំរៀបផ្លែមៀនតាមលំដាប់ថ្នាក់នៅទីកន្លែងម្លប់ត្រជាក់
- ជ្រើសរើសផ្លែដែលស្អុយចេញដើម្បីការពារការឆ្លងមេរោគ
- ប្រសិនបើផ្លែមៀនប្រឡាក់ធូលី យើងត្រូវបាញ់ទឹកលាង ហើយសំដិលវាឱ្យស្ងួត។



## ៣) ជ្រើសរើស

- ត្រូវជ្រើសរើសផ្លែដាក់តាមដើម ឬប្រភេទពូជនិមួយៗ
- ដាក់ឱ្យបានត្រឹមត្រូវតាមប្រភេទលេខ ១ (ផ្លែធំ), លេខ ២ (ផ្លែធំល្មម), លេខ ៣ (ផ្លែតូច) និងលេខ ៤។ ដើម្បីទាក់ទាញអតិថិជន និងរក្សាតំលៃវាឱ្យបានខ្ពស់ជានិច្ច។



## ៤) ការវេចខ្ចប់

- គួរធ្វើឡើងទៅតាមប្រភេទគុណភាពនិមួយៗ ដែលបានជ្រើសរើស ឬក៏ដាក់បញ្ចូលគ្នាទាំង ៣ ប្រភេទ (លេខ ១, ២ និង ៣) តែធ្វើយ៉ាងណាឱ្យលេខ ១ នៅលើគេ
- ការតំរៀបផ្លែមៀនដាក់កញ្ជើជុំវិញតាមស្រទាប់ ដោយយកទងនៅកណ្តាល ហើយដាក់ផ្លែរាយសង្កត់

- នៅពីលើទងកណ្ដាល ដើម្បីកុំឱ្យវារង្គើនៅពេលដឹកជញ្ជូន
- ការវេចខ្ចប់ដោយប្រើកញ្ជេ ឬកន្ត្រក ហើយប្រើស្លឹកស្រស់របស់វាដាក់ជុំវិញលើក្រោម និងចន្លោះដើម្បីរក្សាគុណភាពសំរស់ និងក្លិនរបស់វា។




## ៥) ការដឹកជញ្ជូន

- យើងអាចប្រើឡាន ឬម៉ូតូ
- តំរៀបកញ្ជេជាថ្នាក់ៗ ជៀសវាងការប៉ះទង្គិចខ្លាំង
- ដាក់គំរបសើមដើម្បីរក្សាភាពត្រជាក់ឱ្យបានស្មើល្អ។



## ៦) ការស្តុកទុក

- រក្សាទុកនៅទីតាំងដែលមានអាកាសធាតុត្រជាក់ និងមានខ្យល់ចេញចូលល្អ (ម្លប់)
- រក្សាទុកដោយដាក់ផ្លែមៀននៅក្នុងកញ្ជេ រុំស្លឹកចេកស្រស់ពីរជាន់ ហើយយើងអាចរក្សាវាទុកបាន ៣-៤ ថ្ងៃ
- គ្របក្រណាត់សើមគ្របលើកញ្ជេដើម្បីជំនួយឱ្យកាត់បន្ថយការខ្សោះជាតិទឹករបស់ផ្លែមៀន។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

បូ ការ នេត សុខ ញើង វណ្ណា និង វង្ស ស៊ីវឿន

# វិធីសាស្ត្រគ្រប់គ្រង ផ្លែមៀន ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ការប្រមូលផលខ្ទឹមស្លឹកឱ្យបានល្អមាន ដូចជា :

- ការប្រមូលផលខ្ទឹមស្លឹកនេះ នៅពេលវាចាស់ល្មម គឺចាប់ពី អាយុ ៣៥ ទៅ ៤៥ ថ្ងៃ ដោយសំគាល់ឃើញស្លឹករបស់វាឡើងម្បៀ និងកមើមរបស់វាឡើងស្ងួច
- យើងអាចដកចាប់នឹងដៃ ប៉ុន្តែចាប់ជិតគល់វាបន្តិចកុំឱ្យដាច់មើម។ បើសិនដីរឹងយើងគួរយកចបជីក ឬកូនរនាស់ ធ្មេញវែងគាស់វាជាមុនសិន ទើបប្រមូលវា
- យើងគួរប្រមូលផលព្រឹកចាប់ពីម៉ោង ៧ ដល់ ម៉ោង ១១ និងល្ងាចពីម៉ោង ២ ដល់ម៉ោង ៥
- យើងគួរប្រមូលផលនៅពេលស្រស់ទឹកសន្សើម គ្មានភ្លៀង ដើម្បីការពារកុំឱ្យស្លឹកវាស្រួយដែលអាចបាក់បែកច្រើន
- ពេលប្រមូលផលត្រូវឆាប់យកមកទុកក្នុងម្លប់ ដើម្បីកុំឱ្យត្រូវកំដៅថ្ងៃខ្លាំងពេក ងាយទទួលការខូចខាតដោយបាត់ជាតិទឹក និងស្រកទំងន់មកពីស្វិតស្រពោន
- កុំធ្វើការប្រមូលផលនៅពេលមានភ្លៀង ព្រោះធ្វើឱ្យខ្ទឹមងាយរលួយ។





## ២) ការសំអាត

ដើម្បីឱ្យផលិតផលមានគុណភាពល្អ ហើយមានសោភ័ណភាព និងមានតំលៃខ្ពស់គាប់ភ្នែកអតិថិជន យើងគួរសំអាតវាឱ្យស្អាតដូចតទៅ :

- បេះសំអាតស្លឹកបាក់ ខូចខាត ងាប់ ស្អុយរលួយចោល
- ធ្វើការកាត់ឫសបន្តិចដើម្បីកុំឱ្យនៅជាប់ដី
- កាត់រួចលាងទឹកសំអាតត្រឹមគល់បានហើយ បើមានស្នាមប្រឡាក់ដីធូលី
- ក្នុងការសំអាត យើងត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន ដើម្បីកុំឱ្យខ្ទឹមស្លឹកងាយទទួលការបាក់បែក នាំឱ្យឆាប់ខូចទុកមិនបានយូរ
- ចំពោះតំរូវការអតិថិជន គឺយើងអាចធ្វើការសំអាតគល់ខ្ទឹម ហើយលក់ភ្លាម១





## ៣) ការវេចខ្ចប់ និងដឹកជញ្ជូន

ក្រោយពីការសំអាតរួច ដើម្បីមានការងាយស្រួលក្នុងការដឹកជញ្ជូនទៅកាន់ទីផ្សារ យើងគួរធ្វើការវេចខ្ចប់ដូចខាងក្រោម :

- ចងវាជាដុំតូច១ (កន្លះ ឬ ១ គ.ក្រ) ដោយប្រើខ្សែកំប្លោក ឬខ្សែចេក ដោយយកស្លឹកចេក ឬស្លឹកឈូកស្រស់ហ៊ុំព័ទ្ធជុំវិញ ដើម្បីរក្សាពណ៌ និងកាត់បន្ថយការប៉ះទង្គិច
- គេត្រូវតំរៀបក្នុងខេង ឬជាលជាជាន់១ តំរៀបពីលើគ្នា
- ខេង ឬជាលត្រូវហ៊ុំព័ទ្ធដោយស្លឹកចេក ឬក្រណាត់បាវ និងខាងក្រោមខេង ឬជាល (បាត) ត្រូវទ្រាប់ស្លឹកចេកដែលមានកំរាស់ពី ១ ទៅ ២ សង្ទីម៉ែត្រ
- ពេលដាក់ក្នុងខេង ឬជាល យើងមិនត្រូវសង្កត់វាទេ
- តំរៀបគល់ខ្ទឹមចេញខាងក្រៅ

- ពេលដឹកមកកាន់ទីផ្សារ យើងត្រូវគ្របក្រណាត់សើម ពីលើ ការពារកំដៅ និងធូលីដីប្រឡាក់

- ក្នុងករណីខ្លះ គេក៏អាចដាក់ក្នុងបាវ ឬការ៉ុងបានដែរ តែការដឹកជញ្ជូនត្រូវប្រើរថយន្ត ដោយតំរៀបបាវ ឬការ៉ុងនោះទន្ទឹមគ្នា ជៀសវាងការដាក់គរលើគ្នា។









## ៤) ការស្តុកទុក

ដើម្បីកាត់បន្ថយការខូចខាត និងរក្សាទុកឱ្យបានយូរនោះ យើងគួរគប្បីធ្វើដូចតទៅ :

- ជញ្ជូនវាដាក់ក្នុងម្លប់ សំដិលវាឱ្យត្រជាក់សិនទើបធ្វើការសំអាតជាក្រោយ តែមិនត្រូវកាត់ឫសវាចេញទេ

- ក្នុងករណីទុកបានយូរថ្ងៃ គេត្រូវពង្រាយលើគ្រែ ឬចានដែលធ្វើឱ្យស្តើងល្មម ឱ្យមានខ្យល់ចេញចូលបានល្អ និងឧស្សាហ៍ប្រោះទឹក (១ ថ្ងៃ ២ ដង) ឬគ្របក្រណាត់សើមពីលើ។ ក្នុងករណីនេះ គេទុកបាន ១ ទៅ ២ ថ្ងៃ

- ក្នុងករណីខ្លះ យើងអាចទុកវាដោយបញ្ឈរក្នុងចានដែកដែលមានទឹក ២-៣ ធីង ហើយក្នុងមួយថ្ងៃប្តូរទឹកម្តងចេញ។ គេទុកក្នុងចានដែកនេះ ត្រូវដាក់ក្នុងម្លប់ត្រជាក់ល្អ ហើយមិនត្រូវប៉ះវាឡើយនៅពេលទុកដាក់នោះ។ ក្នុងករណីនេះ យើងអាចរក្សាទុកបានពី ២ ទៅ ៣ ថ្ងៃ។






**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

រស់ ប៊ុនលី ប្រាក់ វ៉ា និង ហុក ឆេង


# វិធីសាស្ត្រគ្រប់គ្រង

# ខ្ទឹមស្លឹក

## ក្រោយពេលប្រមូលផល








មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement
Agricole Cambodgien

IIRR

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural
Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណៃយ
Funded by McKnight Foundation

## ១) ការប្រមូលផល

លក្ខណៈល្អប្រសើរក្នុងការប្រមូលផលប្រភេទផ្កាចំរុះឱ្យបានសមសប យើងគួរគប្បីអនុវត្ត ដូចខាងក្រោម :

- ផ្កាដែលយើងបញ្ចូលមានដូចជា សិរមាន់ ទំហ៊ូ ដំណក់ទឹកភ្លៀង ប៉ៃលិន ស្បៃរឿង ។ល។ យើងត្រូវកាត់ មែក ឬខ្នែងវាឱ្យមានប្រវែងសមស្រប
- ត្រូវប្រមូលផលផ្កាណាដែលមានអាយុល្មមប្រមូល ក្រពុំមិនសូវរីកធំ ឬរីកច្រើនពេក
- យើងត្រូវកាត់ផ្កាណាដែលល្អ ហើយកាត់ដល់គល់ដី ចំពោះផ្កាចន្ទ និងផ្កាឯទៀត។ ប៉ុន្តែផ្កាសេប្រាយើងគួរយកដៃចាប់ដក ដោយកាន់ឱ្យដល់គុលស៊ុបល្អ
- យើងកាត់នៅពេលស្រស់ទឹកសន្សើម ឬគ្មានភ្លៀង ហើយមិនក្តៅខ្លាំងពេក គឺពីម៉ោង ៧:៣០-១០ ព្រឹក និងពីម៉ោង ៣-៥ ល្ងាច
- ប្រើកាំបិតមុតល្អដើម្បីកាត់ផ្កា។ យើងកាត់ផ្កាជារាងចំណិតត្រសក់
- រុំផ្កាជាមួយស្លឹកចេកស្រស់ដើម្បីការពារកុំឱ្យផ្កាស្រពោនពេលដឹកជញ្ជូនវាពីរងមកដល់ផ្ទះ។

## ២) ការសំអាត



ក្រោយពីការប្រមូលផល យើងគួរធ្វើការសំអាត ដើម្បីឱ្យមានភាពស្រស់ល្អគួរឱ្យចាប់អារម្មណ៍ នោះយើងគួរអនុវត្តចំណុចខ្លះៗដូចខាងក្រោម :

- កាត់មែកផ្កាជាចំណែកៗ ងាយស្រួលចងដុំ
- ជ្រើសរើសមែកផ្កាដែលស្អុយរលួយ ផ្ការីកជ្រុល ឬខ្ចីមិនល្អចេញ។



## ៣) ការចងជាបាច់

- ចងដុំៗ ដែលមានផ្កាពី ៥-១២ មុខបញ្ចូលគ្នាដែលចងដោយខ្សែចេក ឬខ្សែកំប្លោក
- កាត់គល់ផ្កាដែលចងនោះទុកត្រឹម ៥០-៧០ ស.ម ឬ ៥-៧ តឹក
- លាងសំអាតគល់ផ្កាដែលប្រឡាក់ឱ្យបានល្អ
- កាត់ព្រយខ្សែដែលចងនោះចេញ បើវែងពេកនាំឱ្យខូចសោភ័ណភាព។





## ៤) ការវេចខ្ចប់ដើម្បីដឹកជញ្ជូន

ក្រោយពីការចងជាដុំៗរួច យើងធ្វើការវេចខ្ចប់ដើម្បីងាយស្រួលដឹកជញ្ជូនមកកាន់ទីផ្សារ។ យើងគួរអនុវត្តដូចចំណុចខាងក្រោម :

- ចងផ្កាជាដុំៗ ដែលមានពី ៥០-១០០ ដុំបញ្ចូលគ្នា
- ដាក់តំរៀបផ្កាក្នុងជាល កញ្ជេ អង្រើង ដែលមានហ៊ុំស្លឹកចេកទ្រាប់បាតដែលមានកំរាស់ ២-៣ ជាន់ ការពារការទង្គិចគ្នាខ្លាំង

- ដាក់ក្រណាត់សើមគ្របពីលើការពារដីហុយប្រឡាក់ និងរក្សាឱ្យវាមានសំរស់យូរ
- ការតំរៀបផ្កាដោយយកគល់របស់វាគងលើគ្នាជាបន្ត-បន្ទាប់ដោយដាក់ផ្ទុយគ្នា
- កុំដាក់កញ្ចេ ឬជាលត្រួតលើគ្នានៅពេលដឹកជញ្ជូន
- ការដឹកជញ្ជូនគួរធ្វើនៅពេលយប់ចន្លោះពីម៉ោង ៥ ល្ងាច ដល់ម៉ោង ៧ ព្រឹក ដែលមានខ្យល់អាកាសត្រជាក់ល្អ។





## ៥) <u>ការស្តុកទុក</u>

ដើម្បីទុកផលិតផលនេះឱ្យបានយូរ យើងគួរទុកដាក់វាឱ្យបានសមស្រប ដូចជា :

- ទុកក្នុងម្លប់ក្រោមផ្ទះ ឬរោង ក្រោមម្លប់ឈើមានអាកាសធាតុត្រជាក់ និងខ្យល់គ្រប់គ្រាន់
- ដាក់គល់ត្រាំទឹក (លាយជាមួយសាច់ជូរ និងអាស្ពៀ-រីន) ជំរៅ ២-៣ ធ្នឹង ដាក់ក្នុងបាសាំង ពាង ឬចានដែកបោត ដោយយកក្រណាត់ ឬបាវសើម ហ៊ុំព័ទ្ធជុំវិញ តែកុំឱ្យប៉ះលើផ្កា
- យកក្រមាសើម ឬក្រណាត់គ្របពីលើការពារកុំឱ្យវាប៉ះកំដៅ
- កុំប៉ះពាល់វានៅពេលទុកដាក់ ហើយកុំដាក់វាក្រាស់ពេក ជាហេតុនាំឱ្យខ្យល់ចេញចូលមិនគ្រប់គ្រាន់ងាយនឹងរលួយបាន
- ក្នុងករណីនេះ យើងអាចទុកវាបាន ២-៣ ថ្ងៃ ដោយពុំមានបាត់បង់សំរស់ឡើយ
- យើងអាចរុំក្រណាត់សើមជុំវិញបាច់ផ្កា នៅពេលយើងរក្សាវាទុក



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

ហែម ចាត់ ហែម ញឿន អួន ថុល និង ឌុក ម៉ៅ

# វិធីសាស្ត្រគ្រប់គ្រង

# ផ្កាចំរុះចងជាជុំ

## ក្រោយពេលប្រមូលផល



CEDAC
មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

IIRR
វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ដើម្បីប្រមូលផលផ្កាចន្ទឱ្យបានល្អត្រឹមត្រូវ យើងគួរត្រូវយកចិត្តទុកដាក់លើកត្តាមួយចំនួនដូចខាងក្រោម :

- សង្កេតឃើញទងផ្កាចេញកញ្ចុំអស់ ហើយមានពកស១ច្រើន ( ការកាត់របៀបនេះសំរាប់លក់ជាទង )
- អាចកាត់បាននៅពេលគេសង្កេតឃើញកញ្ចុំនៃផ្ការីកប្រមាណ ២០-៣០% ( ការកាត់របៀបនេះសំរាប់យកទៅចងជាមួយផ្កាផ្សេងទៀត )
- គួរប្រមូលផលបាននៅពេលព្រឹកចាប់ពីម៉ោង ៨-១១ និងការប្រមូលផលនៅពេលល្ងាចចាប់ពីម៉ោង ៣-៥។ វាជាពេលវេលាមួយល្អសំរាប់ផ្កាចន្ទ ព្រោះផ្កាមានសភាពរឹងមាំល្អ ស្រស់ទឹកសន្សើមដែលអាចធ្វើឱ្យផ្កាមិនងាយរលួយបាន
- ពេលប្រមូលផល យើងត្រូវជ្រើសរើសយកកាំបិតចុងស្រួចមុតល្អ ដោយកាត់ធ្វើយ៉ាងប្រុងប្រយ័ត្នបំផុត ដើម្បីកុំឱ្យខូចគល់ផ្កា។ កាត់ជាចំណិតត្រសក់ ហើយទុកទងឱ្យបានវែងល្អ ដើម្បីទុកបានយូរ និងអាចធ្វើការតំរឹមបានសមស្របតាមសេចក្តីត្រូវការ។ នៅពេលកាត់ ធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់កូនទងតូច១ ផ្សេងទៀត និងធ្វើឱ្យដើមមេមានដំបៅ
- អាចប្រមូលផលនៅពេលមានអាកាសធាតុស្ងួត ប៉ុន្តែមិនត្រូវឱ្យប៉ះពាល់ផ្ទាល់កំដៅព្រះអាទិត្យទេ
- ជំងឺផ្សេង១ ជាពិសេសផ្សិតអាចកើតមានឡើងយ៉ាងឆាប់រហ័សនៅពេលដែលយើងប្រមូលផលភ្លាម១ បន្ទាប់ពីមានភ្លៀងធ្លាក់។




## ២) ការតំរឹម និងការសំអាត

ក្រោយពីប្រមូលផលរួច ដើម្បីឱ្យផ្កាមានសភាពល្អ យើងធ្វើការសំអាត និងតំរឹមដូចតទៅ :

- ត្រូវដឹកជញ្ជូនដាក់ក្នុងម្លប់ត្រជាក់ភ្លាម១ ជៀសវាងកុំឱ្យវាស្វិតស្រពោនទាន់
- ការតំរឹមធ្វើឡើងជាពីរប្រភេទគឺ : លេខ ១ និងលេខ ២ ដោយលេខ ១ ទុកប្រវែង ៧-៨ តឹក លេខ ២ ទុក ៥ តឹក។ ការតំរឹម យើងយកវាទៅតំរៀបលើដុំឈើ ដើម្បីកាត់វាកុំឱ្យមានបែកទង ដែលជាហេតុនាំឱ្យងាយរលួយស្អុយ
- យើងត្រូវបេះស្លឹកដែលខូចចោល ឬស្លឹកមានស្លាមសត្វបំផ្លាញ ដើម្បីការពារមេរោគឆ្លង
- ការតំរឹម និងការសំអាតនេះធ្វើឡើងនៅក្រោមម្លប់ត្រជាក់ ឬក្រោមផ្ទះ។



## ៣) ការជ្រើសរើស

ផ្កាចន្ទជាប្រភេទផ្កាមេ យើងអាចប្រើវាតែឯក-ឯងក៏បាន ឬជាចំរុះជាមួយផ្កាផ្សេងទៀតក៏បាន។ ដូច្នេះការជ្រើសរើសផ្កាចន្ទ គឺមានបីប្រភេទគឺ:

ផ្កាចន្ទ ដែលចាត់ទុកជាប្រភេទលេខ ១ គឺមាន : ដងដើមចាប់ពី ៧ តឹកឡើងទៅ កញ្ចុំផ្កាធំល្អ ហើយរីកមិនលើសពី ២០%។ ចំពោះលេខ ២ វិញ មាន ដើមដងចន្លោះពី ៥-៧ តឹក មានកញ្ចុំផ្កាល្អ និងរីកមិន លើសពី ៣០% ក្រៅពីនោះ យើងចាត់ទុកប្រភេទផ្កាលេខ ៣ ដែលអាចយកទៅចង លក់ជាមួយផ្កាផ្សេងទៀត។



## ១) ការប្រមូលផល

ដើម្បីរក្សាទុកផ្លែស្វាយឱ្យបានយូរ និងមានគុណភាពល្អ យើងត្រូវពិនិត្យមើលលក្ខណៈមួយចំនួន ដូចជា:

- ផ្លែដាក់ម្សៅពេញទំហឹង មានភាពរលោង ឬក្រហមក្បាល ហើយសំបកស្តើង និងគ្រាប់របស់វារឹង
- ការប្រមូលផលធ្វើឡើងនៅពេលថ្ងៃក្តៅសីតុណ្ហភាពជាមធ្យមពី ២៨-៣៤ អង្សាសេ ដើម្បីឱ្យវាស្រក់ជ័រអស់ ហើយមិនច្រើនពេក គឺពេលវេលាពីម៉ោង ៩ ព្រឹក ដល់ម៉ោង ៣ រសៀល
- ប្រើដៃ ឬកន្ត្រក (កន្តរ) ធ្វើយ៉ាងណារក្សាសណ្តង់របស់វាឱ្យនៅវែង ដើម្បីការពារកុំឱ្យស្រក់ជ័រលើគេ ឬស្រក់ជ័រច្រើនពេកនាំឱ្យខ្សោះរសជាតិ និងឆាប់ខូច។



## ២) ការតំរឹម និងសំរក់ជ័រ

- កាត់សណ្តង់វាចេញដោយរក្សាតែ ២ ទៅ ៥ ធ្នឹងប៉ុណ្ណោះ ដើម្បីការពារកុំឱ្យចេញជ័រច្រើនពេក
- តំរៀបគ្នានៅទីមួយដោយដាក់ក្បាលផ្កេកចុះក្រោម ដើម្បីឱ្យស្រក់ជ័រអស់ ហើយជៀសវាងការដាក់គរលើគ្នា នាំឱ្យហាប់ក្រៅជាំ ឬប្រឡាក់ជ័រ។



## ៣) ការជ្រើសរើស

- ត្រូវធ្វើការជ្រើសរើសផ្លែតាមប្រភេទលេខ ១, លេខ ២ និងលេខ ៣ ដែលអាចទាក់ទាញអតិថិជន និងដើម្បីឱ្យមានតំលៃខ្ពស់
- យកផ្លែណាដែលមានរមូល ឬជាំចេញ ដើម្បីការពារក្នុងការបញ្ចេញធាតុ ឧស្ម័នអេទីឡែន ដែលបណ្តាលឱ្យឆ្លង ស្អុយដល់ផ្លែដទៃទៀត។



## ៤) ការសំអាត

- ជូតសំអាតផ្លែណាដែលមានប្រលាក់ជ័រ ឬសារធាតុខ្មៅនៅលើផ្លែរបស់វា ដោយប្រើក្រណាត់ទន់សើម ជៀសវាងការហោងទឹក នាំឱ្យឆាប់រលួយ ដោយវាស្រូបយកទឹកមិនល្អ ឬច្រើនពេកចូលក្នុងផ្លែ។



## ៥) ការវេចខ្ចប់ និងដឹកជញ្ជូន

- វេចខ្ចប់តែផ្លែណាដែលមានទំហំប៉ុនគ្នា ដូច្នេះវាអាចមិននៅសល់ចន្លោះច្រើននៅក្នុងធុងកាតុង ឬឡាំង
- ត្រូវប្រើសារធាតុទន់ ស្ពោតសំរាប់ការពារផ្លែកុំឱ្យប៉ះទង្គិចខ្លាំង

- ប្រើកាតុង ឡាំង ឬកញ្ជេ ដោយទ្រាប់ស្លឹក ឬចំបើង ព័ទ្ធជុំវិញដើម្បីការពារការប៉ះទង្គិច
- ដាក់ស្នោស្តោតការពារផ្លែដើម្បីជៀសវាងការហាប់ ឬទង្គិចខ្លាំង
- យើងអាចដាក់ផ្លែស្វាយឱ្យត្រឹមតែមាត់តែមឡាំង ឬកញ្ជេ ដើម្បីជៀសវាងការកំពប់ ។





៦) <u>**ការស្តុកទុក ឬបន្ទុំ**</u>

- ប្រសិនបើយើងមិនទាន់ចង់បន្ទុំវាទេ គឺយើងរក្សាទុកនៅកន្លែងត្រជាក់ និងមានខ្យល់ចេញចូលល្អ ដោយមិនដាក់គរលើគ្នា ( យើងអាចរក្សាទុកបានពី ៥-៦ ថ្ងៃ)

- ឬមួយយកវាទៅបន្ទុំក្នុងក្អម ឬពាង ដោយប្រើស្លឹកឈើ ដូចជា ទំពូង កន្ទំថេត ម្រុំ អង្គាដី ។ល។ រួចដុតធូប ដើម្បីឱ្យមានផ្សែងសំរាប់កាត់សារធាតុ បែតងដែលធ្វើឱ្យវាឆាប់ទុំ ឬយើងអាចប្រើថ្នស្អុយ ដើម្បីជំនួសក៏បាន ( តែគុណភាពមិនសូវល្អ)
- ការបន្ទុំរយៈពេល ២ ទៅ ៣ ថ្ងៃ ទើបទុំល្អ និងមានរសជាតិឆ្ងាញ់
- យើងត្រូវបន្ទុំតែស្វាយណាដែលមិនបែក ឬស្វាយចាស់ល្អ បើមិនដូច្នេះទេ វាបណ្តាលឱ្យខូចគុណភាពដល់ស្វាយដទៃ ឬអាចបណ្តាលឱ្យស្វាយនោះមានរសជាតិមិនឆ្ងាញ់ ។




---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

រិន ប្រិយ និង រិន ញឹម

# វិធីសាស្ត្រគ្រប់គ្រង

# ផ្លែស្វាយ

## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
**Funded by McKnight Foundation**

## ១) ការប្រមូលផល

ចំពោះដំណាំស្ពៃ គេអាចប្រមូលផលនៅពេលដែលគេសង្កេតឃើញថា :

- មានស្រទាប់ម្សៅស្ថិតនៅលើធាងផ្នែកគល់របស់វា
- វាពេញអាយុល្អ គឺពី ២ ខែទៅ ២ ខែកន្លះ
- ប្រមូលផលនៅពេលដែលមេឃត្រជាក់ ហើយស្ងួតសំណើម ព្រោះធាងរបស់វាស្រួយណាស់នៅពេលមេឃត្រជាក់ (ពេលព្រឹកចាប់ពីម៉ោង ៩ និងពេលរសៀលចាប់ពីម៉ោង ៣)។ ក្នុងការប្រមូលផល គឺគេកាត់ ដោយប្រើកូនកាំបិតដែលមុតល្អ
- ពេលកាត់ត្រូវប្រុងប្រយ័ត្ន ជៀសវាងការប៉ះទង្គិចខ្លាំង។



- ត្រូវប្រមូលស្ពៃជ្រក់ចូលក្នុងម្លប់ភ្លាមៗ បន្ទាប់ពីកាត់ហើយ ជៀសវាងកុំឱ្យវាត្រូវកំដៅថ្ងៃ

## ២) ការសំអាត

- ក្រោយពេលប្រមូលផលរួច គេមិនលាងសំអាតដោយទឹកទេ ព្រោះវាអាចបៀមទឹក និងធ្វើឱ្យស្ពៃឆាប់ជាំ និងងាយរលួយ។ គេគ្រាន់តែកាត់ស្លឹកដែលចាស់ៗចោលតែប៉ុណ្ណោះ
- រួចដាក់សំដិលក្រោមម្លប់រយៈពេលពី ៣០ នាទី ដោយយោងទៅតាមអាកាសធាតុក្តៅ ឬត្រជាក់
- កុំឱ្យស្រពោនពេក តែប្រចាច់ទៅមិនបាក់
- ត្រូវបេះស្លឹករលួយចេញដើម្បីកុំឱ្យឆ្លង។



## ៣) ការជ្រើសរើស ប្រដាប់ខ្ចប់

បន្ទាប់ពីសំដិលរួច គេតំរៀបចូលទៅក្នុងខេងដែកកញ្ជើដែលមានរំបារ ឬដាក់លើរ៉ឺម៉ក ឬឡានតែម្តង ដោយមានទ្រាប់ និងគ្របពីលើដោយប្រើស្លឹកស្រស់ (ស្លឹកចេកស្រស់)។ ការតំរៀប គឺដាក់គល់ស្ពៃចេញក្រៅ ហើយជារង្វង់ បើដាក់ក្នុងកញ្ជេ។ កុំដាក់ឱ្យវាពេញហួសមាត់កញ្ជេ។





## ៤) ការដឹកជញ្ជូន

- ការដឹកជញ្ជូន គឺគេអាចដឹកបាននៅពេលព្រឹក រសៀល និងពេលយប់ ដោយម៉ូតូ រ៉ឺម៉ក ឬឡាន ទៅកាន់ទីផ្សារ

- រៀបកញ្ចេជាថ្នាក់ៗ ហើយជៀសវាងការអង្គុយលើ ឬដាក់អ្វីធ្ងន់ពីលើនាំឱ្យបាក់បែក ឬក្តៅហាប់រលួយ
- ខេងត្រូវរៀបជាថ្នាក់ៗ ដោយមានឈើកល់
- ត្រូវគ្របខេងនឹងក្រណាត់សើមការពារធូលី។





## ៥) ការស្តុកទុក

ស្ពៃជ្រក់អាចទុកបាន ១ យប់ ២ ថ្ងៃ ដោយគេធ្វើការសំដិលវានៅលើគ្រែ នៅពេលយប់ទុកវាហាលសន្សើម និងពេលថ្ងៃយកចូលម្លប់។ បើសិនជាទុករយៈពេល ២ យប់ អាចបាត់បង់រហូតដល់ ៣៥% តែវាអាចយកទៅធ្វើជ្រក់បាន។ ដាក់សំដិលកន្លែងម្លប់ ហើយពេលយប់អាចដាក់ឱ្យត្រូវសន្សើមបាន តែមិនឱ្យត្រូវថ្ងៃទេ។ នៅពេលដែលយើងស្តុកទុកអាចប្រើប្រាស់កំបោរ ឬសាច់ដូរលាបគល់របស់វាដើម្បីឱ្យអាចរក្សាទុកបានយូរ។




**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

ស៊ សុង ម៉ៅ ចិញ្ច និង វិញ ស៊ាម


# វិធីសាស្ត្រគ្រប់គ្រង ស្ពៃជ្រក់ ក្រោយពេលប្រមូលផល




CEDAC
មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

IIRR
វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណោយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ក្រោយដាំបានរយៈពេល ៦ ខែ វាអាចចេញផ្កាឱ្យយើងបេះបាន។ ចំពោះការបេះ យើងមិនចាំបាច់ទុកឱ្យរីកទាន់ទេ គឺជាទូទៅយើងសំគាល់ថា :

- ល្មមនឹងបេះនៅពេលផ្កានោះស្ទើររីក តែពុំទាន់បែកមាត់ចាបទេ ហើយពណ៌របស់វាសំគាល់ឃើញថាសភ្លឺថ្លា។
- ការបេះផ្កាម្លិះយោងទៅតាមតំរូវការជាក់ស្តែង បើផ្កានោះត្រូវការយកមកប្រើប្រាស់ភ្លាមៗ (ចាក់ភួង) គឺបេះមិនឱ្យជាប់គល់ទងទេ។ ប៉ុន្តែ បើយើងមានបំណងរក្សាទុកយូរ ការបេះត្រូវបេះទាំងគល់ទង។ ធ្វើយ៉ាងនេះអាចរក្សាទុកបានដោយពុំបាត់គុណភាពឡើយ ត្រូវកាត់ផ្កាថ្នមៗ កុំឱ្យបែកផ្កា។
- ពេលវេលានៃការប្រមូលផល ត្រូវធ្វើឡើងពេលអាកាសធាតុត្រជាក់ ហើយស្រស់ទឹក ឬទឹកសន្សើម ធ្វើយ៉ាងណាឱ្យផ្កាអាចរក្សាក្លិន និងមានគុណភាពល្អបានយូរ។ យកល្អចាប់ពីម៉ោង ៨ ព្រឹកឡើងទៅ។



## ២) ការជ្រើសរើសគុណភាពផ្កា

ក្រោយពីប្រមូលផលពីដើមរួច គេត្រូវជ្រើសរើសបែងចែកផ្កាជា ២ ប្រភេទផ្សេងគ្នា : ប្រភេទទី ១ សំរាប់ចាក់ភួង (ភួងដៃ ភួងក និងភួងធំៗ សំរាប់ពិធីបុណ្យ ការ និងថ្វាយព្រះជាដើម) និងលេខ ២ (ផ្ការីក និងផ្កាតូចៗ មិនអាចចាក់ភួងបាន) សំរាប់លក់ឱ្យគេធ្វើតែ (ភេសជ្ជៈ)។



## ៣) ការចាក់ភួងផ្កាសំរាប់លក់

ចំពោះផ្កាម្លិះមុនពេលចាក់ភួង យើងដាក់ត្រាំទឹក ១០ ទៅ ១៥ នាទីសិន ដើម្បីឱ្យងាយស្រួលក្នុងការចាក់។ ប៉ុន្តែតាមបទពិសោធន៍កន្លងមក ការត្រាំផ្កាក្នុងទឹកត្រជាក់មុនយកទៅចាក់ជាភួង ផ្កានេះទុកពុំបានយូរបណ្តាលឱ្យវាឆាប់ជាំ និងរលួយ។ បើខានមិនបាន យកល្អយើងលាងជាមួយទឹកកក ដើម្បីឱ្យវារឹងងាយស្រួលចាក់ ហើយអាចកាត់បន្ថយជាតិទឹកនៅក្នុងខ្លួនរបស់វា។





## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

ផលផ្កាម្លិះ ក្រោយពីប្រមូលត្រូវធ្វើយ៉ាងណាវេចខ្ចប់ឱ្យបានល្អ បើពុំដូច្នោះទេ គឺវារីក ឬរលួយខូចអស់តែម្តង។ យើងត្រូវយកផ្កាខ្ចប់ក្នុងស្បោងប្លាស្ទិក រួចក្លាស្សេទឹកកក ដោយធ្វើយ៉ាងណាចង ឬរុំវាឱ្យបានជិតល្អមុននឹងដាក់ក្លាស្សេក្នុងធុង។ ចំពោះផ្កាដែលចាក់ចង្កាក់ ឬភួងរួច ហើយ យើងត្រូវក្លាស្សេជាមួយទឹកកកផ្ទាល់តែម្តង ហើយធ្វើយ៉ាងណាកុំឱ្យមានទឹកក្នុងធុងឱ្យសោះ នាំឱ្យវាជ្រាបចូលដល់ផ្កា ដែលអាចធ្វើឱ្យផ្ការលួយបាន។

ឯការដឹកជញ្ជូនវិញ គឺយកធុងផ្កាកំពុងក្លាសេទៅដាក់លើម៉ូតូ រ៉ឺម៉ក ឬឡានតែម្តង។ តែធ្វើយ៉ាងណាដឹកនៅពេលត្រជាក់ ដើម្បីកុំឱ្យទឹកកកឆាប់រលាយ នាំឱ្យប៉ះពាល់ដល់ផ្កា។







## ៥) ការរក្សាទុកផ្កាម្លិះ

ក្នុងការថែរក្សាទុកផ្កាម្លិះឱ្យបានយូរ យើងត្រូវ :

- ចាក់ជាភួង រួចយកទៅក្លាសេក្នុងទឹកកក។ ការធ្វើរបៀបនេះ អាចរក្សាទុកបានពី ៤ ទៅ ៦ ថ្ងៃ តែនៅមានជាំ ឬរលួយខ្លះ ឯគុណភាពផ្កានៅល្អ អាចលក់បាន
- ប្រើស្បោងប្លាស្ទិកធម្មតា ដែលមានចំណុះពីកន្លះគីឡូទៅ ២ គីឡូក្រាម ច្រកផ្កាម្លិះខ្ចប់ឱ្យជិតល្អ រួចក្លាសេក្នុងធុងទឹកកក ធ្វើយ៉ាងណាកុំឱ្យជ្រាបទឹកចូលក្នុងស្បោង។ ធ្វើរបៀបនេះ យើងអាចរក្សាទុកបានរយៈពេលជិត ២ អាទិត្យ ដោយមានក្លិន និងគុណភាពល្អប្រសើរ។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

នេត សុខ ញើង វណ្ណា ពត បញ្ញារិទ្ធិ ជា សារ៉ុធ ពត ខេត្ត

# វិធីសាស្ត្រគ្រប់គ្រង
# ផ្កាម្លិះ
## ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណោយ
Funded by McKnight Foundation

## ១) ការប្រមូលផល

- ជាទូទៅផ្លែថាវមានរយៈពេលលូតលាស់ ៤០ ទៅ ៤៥ ថ្ងៃ ទើបអាចប្រមូលផលបាន។
- ចំពោះការប្រមូលផល យើងត្រូវពិនិត្យទៅលើអាយុកាលនៃការដុះលូតលាស់របស់វា បើដល់អាយុហើយ យើងត្រូវពិនិត្យទៅលើលក្ខណៈដងដើមរបស់វាទៀត ដោយឃើញវាឡើងលើដីធំល្មម។
- ការប្រមូលផល គឺត្រូវធ្វើឡើងដោយដៃ ចាប់ដកដើមពីក្នុងថ្នាលតែម្តង បើដីថ្នាលនោះផុសល្អ
- ម្យ៉ាងទៀត វិធីល្អបំផុតយើងត្រូវប្រើដៃដែក ចបចក់ដែលមានធ្មេញវែងៗ គាស់វាជាមុនសិនទើបប្រមូលតាមក្រោយជាការល្អ



- កុំស្រោចទឹក ១ ថ្ងៃមុនពេលប្រមូលផល
- យើងអាចធ្វើការប្រមូលផលនៅពេលស្ងួតល្អ ជៀសវាងការប្រឡាក់ ដើម្បីជៀសវាងការឆ្លងជំងឺសំខាន់គឺផ្សិតដែលបណ្តាលឱ្យផ្លែថាវឆាប់ស្អោត
- ពេលដកភ្លាមត្រូវដឹកជញ្ជូនចូលម្លប់ភ្លាម។

## ២) ការសំអាត និងតំរឹម

- ផ្លែថាវក្រោយពីដករួច គឺមិនត្រូវលាងទឹកទេ ពីព្រោះបើលាងវានាំឱ្យឆាប់រលួយ និងស្អោតសាច់ផ្នែកខាងក្នុង
- ការសំអាត គឺគ្រាន់តែបេះដីណាដែលជាប់ជំពេកនៅលើមើមតែប៉ុណ្ណោះ តែមិនត្រូវឱ្យវាជ្រះពេកទេ គឺទុកវាខ្លះដើម្បីការពារសំណើម និងសំបកកុំឱ្យវារលាក
- ការតំរឹម គឺយើងកាត់តែឫសកែវ ឬឫសស្វែវែងៗ ដែលជាប់មើមរបស់វាចេញ និងកាត់ស្លឹករបស់វាដោយទុកចំងាយពីមើមប្រហែល ១ តឹក។



## ៣) ការជ្រើសរើស

ក្រោយពីប្រមូលផល និងកាត់ដើមឫសចេញ ហើយ យើងត្រូវរៀបចែកវាជា ៣ ប្រភេទ គឺប្រភេទលេខ ១ ជ្រើសរើសមើមធំដាក់ម្ខុំ និងទី ២ មើមធំល្មម និងទី ៣ មើមដែលមានខ្វែង ឬមានប៉ះទង្គិចបាក់បែក ដើម្បីយកទៅប្រើប្រាស់ភ្លាមៗ (កែច្នៃធ្វើជាផ្លែប៉ូវជាដើម)។



## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

- ក្រោយពីសំអាត និងជ្រើសរើសរួចមក យើងអាចយកវាទៅតំរៀបក្នុងកញ្ជេដែលមានទ្រាប់ស្លឹកចេក ឬស្លឹករុក្ខជាតិផ្សេងទៀតនៅបាត និងហ៊ុំជុំវិញ
- ក្នុងការដាក់វាទៅក្នុងកញ្ជេ គួររក្សាវាឱ្យនៅមានដីខ្លះៗ នៅជាប់មើមរបស់វា បើមិនដូចនេះទេយើងយកដីខ្សាច់មករោយចន្លោះមើមដែលបានរៀបរួច ដើម្បីរក្សាសំណើម និងកាត់បន្ថយការប៉ះទង្គិច

- យើងតំរៀបវាតាមប្រភេទលេខរបស់វា (លេខ ១, ២ និង ៣) ដោយដាក់មើមរបស់វាផ្ទុយគ្នា ដើម្បីងាយស្រួលក្នុងការរៀប ហើយអាចដាក់ចំណុះបានច្រើន
- ការដឹកជញ្ជូន គួរប្រើឡាន ឬទូកដែលមានចំណុះច្រើន ហើយធ្វើយ៉ាងណាកុំដាក់កញ្ច្រែលើគ្នាដោយផ្ទាល់ ត្រូវតំរៀបជាថ្នាក់ៗ
- ក្នុងពេលធ្វើដំណើរឡាន ឬទូក ត្រូវមានដំបូលការពារកំដៅថ្ងៃ និងធូលី។





## ៥) ការស្តុកទុក

ប្រសិនបើយើងដកភ្លាមយកទៅប្រើប្រាស់ភ្លាមៗ យើងអាចលាងទឹកមើមបាន។ ប៉ុន្តែការលាងទឹកមិនអាចធ្វើឱ្យយើងរក្សាទុកបានយូរទេ គឺបានត្រឹមតែ ១ ទៅ ២ ថ្ងៃប៉ុណ្ណោះ លើសពីនេះវាអាចខូចគុណភាព ដោយធ្វើឱ្យមើមរលួយ ឬស្អោតពីខាងក្នុង។ ដោយឡែក គេអាចរក្សាទុកឆៃថាវបានរយៈពេល ៧ ថ្ងៃ ដោយ យកដីខ្សាច់ក្រាលនៅបាតកញ្ចេ (យកកញ្ចេដែលមានប្រហោងខ្យល់ចេញចូល) កំរាស់ ១ តឹក ។

បន្ទាប់មកយកមើមឆៃថាវដែលបានប្រមូលផល និងសំអាតរួចទៅតំរៀបដាក់ពីលើដីខ្សាច់កំពស់ ៤ តឹក ទើបយកក្រណាត់ដែលជក់ទឹកជ្រលក់ទឹកឱ្យសើមៗ គ្របពីលើ។ បើក្រណាត់ស្ងួត យើងត្រូវបាញ់ទឹកសើមក្រណាត់ឱ្យជាប់ជានិច្ច។ ការធ្វើបែបនេះ យើងអាចរក្សាទុកបានរហូតដល់ ៧ ថ្ងៃ ដោយមិនខូចគុណភាព។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

រស់ ប៊ុនលី និង ឌុល វណ្ណនី

# វិធីសាស្ត្រគ្រប់គ្រង
# ឆៃថាវ
## ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ដើម្បីឱ្យការប្រមូលផលមានដំណើរការល្អ និងកាត់បន្ថយការបាត់បង់ យើងគួរគប្បីអនុវត្តដូចតទៅ :

- យើងអាចប្រមូលផលស្ពៃចង្កឹះនេះបាន លុះត្រាតែវាមានអាយុចាប់ពី ២៨-៣៥ ថ្ងៃ ដោយសំគាល់បានថា "ដើម ធាង មានម្សៅ" ឬក៏ដើមខ្លះមានក្របួចផ្កា
- ការប្រមូលផលភាគច្រើន យើងធ្វើឡើងនៅពេលព្រឹកស្រស់ទឹកសន្សើម ចាប់ពីម៉ោង ៨-១០ ព្រឹក និងពីម៉ោង ២-៤ រសៀល ពីព្រោះពេលនេះសីតុណ្ហភាពត្រជាក់ល្មម ដែលអាចបង្កលក្ខណៈឱ្យស្ពៃស្រពាប់តាមធម្មជាតិបាន។



- ការប្រមូលផលនេះ យើងត្រូវយកកូនកាំបិតស្លាមុត ឬកូនកាំបិតចុងស្រួចមកកាត់ត្រឹមលើដី
- ពេលចាប់ផ្តើមកាត់ត្រូវយកដៃក្តោប ឬក្រសោបធាងថ្នមៗ ហើយទាញតិចៗ ផ្តេកគល់បន្តិចទើបកាត់តែម្តង
- មិនគួរកាត់នៅពេលមានភ្លៀង ហើយមិនត្រូវដាក់ស្ពៃនៅក្រោមពន្លឺថ្ងៃទេ។

## ២) ការតំរឹម ឬសំអាត

ការសំអាត ឬតំរឹមនេះ វាជាការងារមួយចាំបាច់បំផុតដើម្បីកាត់បន្ថយការឆ្លងមេរោគ ធ្វើឱ្យមានសោភ័ណភាព និងទាក់ទាញភ្នែកអ្នកទិញ ឬអតិថិជនផង។ ក្នុងការងារនេះ ការសំអាតស្ពៃចង្កឹះមានលក្ខណៈដូចខាងក្រោម :

- គេធ្វើឡើងភ្លាមៗ នៅពេលកំពុងកាត់តែម្តង ពោលគឺយើងកាត់បណ្តើរ សំអាតបណ្តើរ ដោយបេះធាងណាដែលស្អុយរលួយចេញ ពិសេសធាងក្រោមចាស់ៗ និងធាងណាដែលមានស្លាមសត្វបំផ្លាញ
- យើងមិនត្រូវលាងទឹកស្ពៃចង្កឹះទេ ពីព្រោះវានឹងឆាប់ទទួលរងនូវការលួយស្អុយ ដោយសារជាតិទឹកក្នុងដើមវាច្រើន។

## ៣) ការជ្រើសរើស

ការជ្រើសរើស ក៏អាចធ្វើឱ្យតំលៃបន្លែរបស់យើងខ្ពស់ផងដែរ គឺយើងជ្រើសរើសវាតាមទំហំលេខ ១ លេខ ២ និងលេខ ៣ ដើម្បីងាយស្រួលក្នុងការតំរៀប និងលក់ផងដែរ។



## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

ក្រោយពីការសំអាត ឬតំរឹម និងជ្រើសរើសរួច យើងគួរធ្វើការតំរៀបវាជាដុំៗ (ឬគេហៅថា អ៊ិក) ដែលក្នុងនោះមាន :

- តំរៀបជា អ៊ិកៗ (ពី ១-១,៥ គីឡូ) ក្នុងកញ្ជេឬស្សី ឬជាលដែក ជាស្រទាប់ៗ ដែលក្បាល ឬគល់ចេញមកខាង។ នៅក្នុងកញ្ជេ ឬជាល យើងត្រូវតំរៀបស្លឹកចេកបាតក្រោម ដែលមានកំរាស់ពី ២-៣ សង្ទីម៉ែត្រ ហើយមានហ៊ុំព័ទ្ធសងខាងផង ឬក៏អាចយកបាវមកហ៊ុំព័ទ្ធជំនួសស្លឹកចេក
- នៅក្នុងកញ្ជេ ឬជាលយើងអាចតំរៀបបាន ១០០-១២០ គ.ក្រ តែមិនត្រូវសង្កត់លើបន្លែនោះទេ ជាហេតុ

នាំឱ្យវាបាក់បែក ឬបណ្តាលឱ្យរលួយបាន ហើយដាក់បន្លែឱ្យត្រឹមរឹមកញ្ជេបានហើយ

- ពេលរៀបដាក់ក្នុងជាល ឬកញ្ជេហើយ យើងលើកវាដាក់លើម៉ូតូ រ៉ឺម៉ក ឬឡាន ហើយយើងមិនត្រូវដាក់កញ្ជេគរលើគ្នា ឬអង្គុយលើទេ ដែលនាំឱ្យពេលធ្វើដំណើរ រលាក់សង្កត់ខ្លាំងលើបន្លែ ជាហេតុធ្វើឱ្យបាក់ជាំ។



## ៥) ការស្តុកទុក

- ការស្តុកទុក គឺមិនចាំបាច់កាត់ឫសចេញទេ ព្រោះវាអាចស្តុកទុកបានយូរជាងការកាត់ឫស ដោយសារវាមិនស្វិតបញ្ចេញទឹកខ្លាំង។

ការស្តុកទុកវាជាការចាំបាច់មួយ ដែលយើងគួរតែធ្វើ ការងារនេះត្រូវបានបែងចែកជា ២ គឺការស្តុកទុកនៅលើរងពេលកាត់ភ្លាមដើម្បីឱ្យស្រពោន និងម្យ៉ាងទៀតស្តុកទុកក្រោយពេលប្រមូលផលស្រេចបាច់ហើយ។

## ការស្តុកទុកក្រោយពេលប្រមូលផល

យើងធ្វើឡើងដោយទុកពង្រាយនៅលើគ្រែ ដែលតំរៀបជាជួរៗ តំរៀបឱ្យស្តើងល្មមកុំឱ្យវាហាប់ពេក ទុកប្រឡោះឱ្យខ្យល់ចេញចូលបាន។ ត្រូវទុកកន្លែងណាដែលមានអាកាសធាតុត្រជាក់ ខ្យល់ចេញចូលបាន ហើយមិនត្រូវប៉ះវាទេ តែករណីយូរថ្ងៃ គេអាចប្តូរទីតាំង ឬប្រែវាបាន។ ការទុករបៀបនេះ ស្ពៃចង្កឹះអាចបានត្រឹមតែ ១-២ ថ្ងៃប៉ុណ្ណោះ។ ចំពោះស្ពៃដែលមិនប្រើជីគីមី យើងអាចរក្សាទុកវាបានរហូតដល់ ៦-៨ ថ្ងៃ ដោយប្រើបច្ចេកទេសរបៀបនេះ។



**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

វ៉ុធ វណ្ណនី សឿន ចក់ និង ឌុល វណ្ណនី

# វិធីសាស្ត្រគ្រប់គ្រង
# ស្ពៃចង្កឹះ
# ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
CEDAC
Centre d'Etude et de Développement Agricole Cambodgien

IIRR
វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណៃត
Funded by McKnight Foundation

## ១) ការប្រមូលផល

ដើម្បីឱ្យការប្រមូលផលត្រប់បានល្អ យើងគួរអនុវត្តនូវចំណុចមួយចំនួនដូចខាងក្រោម :

- ត្រូវបេះផ្លែត្រប់ណាដែលមានទំហំធំល្មម ពោលគឺមិនខ្ចីពេក មិនចាស់ពេក
- យើងត្រូវកាត់សណ្តង់ផ្លែ ឬទងដោយកូនកាំបិត ឬកន្ត្រៃមុតល្អ
- ទុកសណ្តង់ប្រវែងប្រហែលមួយចង្អុលដៃ ឬ ៤-៥ ធឹង ដើម្បីកុំឱ្យជ័រចេញច្រើនពីផ្លែ ឬរលួយក្បាលផ្លែ
- យើងបេះ ឬកាត់ នៅម៉ោង ៨-១១ ព្រឹក ឬម៉ោង ២-៥ ល្ងាច ជាពេលដែលស្ងួតសំណើម ហើយពេលថ្ងៃក្តៅខ្លាំងត្រូវដឹកជញ្ជូនចូលម្លប់ភ្លាម១ បន្ទាប់ពីប្រមូលផល
- យើងកាត់ទងសណ្តង់កុំឱ្យបែក ជាហេតុធ្វើឱ្យផ្លែ និងដើមអន់ ហើយវាអាចឆ្លងមេរោគដល់ផ្ការបស់វាទៀត



## ២) ការសំអាត និងជ្រើសរើស

ក្រោយពីប្រមូលផលរួច យើងគួរធ្វើការសំអាត និងជ្រើសរើសជាចាំបាច់ ដើម្បីធ្វើឱ្យផលិតផលរបស់យើងមានសោភ័ណ្ឌភាព ចំណុចដែលត្រូវធ្វើមាន :



- ជ្រើសរើសផ្លែណាដែលស្អុយរលួយចេញ ដើម្បីកុំឱ្យវាឆ្លងដល់គេ
- ចិត្តទងសណ្តង់ចេញខ្លះបើវែងពេក ទុកតែមួយចង្អុលដៃជាការល្អ
- ជ្រើសយកផ្លែដែលមិនប្រក្រតី ដូចជាស្វិត ក្រងិក្រង៉ក់ មានស្នាមសត្វបំផ្លាញ ក្រិនរឹងជាដើម ។ល។
- ជ្រើសរើសយកផ្លែដែលខ្ចីពេក និងចាស់ពេកចេញ
- យើងត្រូវលាងទឹកសំអាតដីភក់ដែលប្រឡាក់ចេញ ដោយប្រើប្រាស់ក្រណាត់សើមដើម្បីជូតវាចេញ កាលណាលាងផ្លែត្រប់ដោយប្រើប្រាស់ទឹកនោះផ្លែត្រប់នឹងស្រូបទឹក ធ្វើឱ្យវាទុកមិនបានយូរ
- យើងត្រូវជ្រើសរើសវាដាក់តាមទំហំផ្លែរបស់វា តាមប្រភេទលេខ ១ លេខ ២ និងសល់ពីនេះជាប្រភេទលេខ ៣។
- ត្រូវយកក្រណាត់ ឬបាវសើមគ្របពីលើការពារកំដៅថ្ងៃ និងធូលីដីហុយប្រឡាក់ ។

## ៣) ការវេចខ្ចប់ និងដឹកជញ្ជូន

ក្រោយពីការសំអាតរួចស្រេចបាច់ហើយ យើងគួរទុកផ្លែត្រប់ឱ្យស្រស់ទឹកសិន ទើបយើងធ្វើការវេចខ្ចប់ដើម្បីងាយស្រួលដឹកជញ្ជូនមកកាន់ទីផ្សារ។ ដើម្បីឱ្យការងារនេះប្រព្រឹត្តទៅក្នុងដំណើរការល្អ សមស្របនឹងសេចក្តីត្រូវការនោះ យើងត្រូវប្រកាន់ខ្ជាប់នូវចំណុចដូចខាងក្រោម :

- ត្រូវយកផ្លែត្រប់តំរៀបដាក់ក្នុងកញ្ជ្រែ ឬជាល តាមប្រភេទលេខ ១ លេខ ២ និងលេខ ៣ ដើម្បីងាយស្រួល កំណត់តំលៃ
- កញ្ជ្រែ ឬជាល ត្រូវទ្រាប់ស្លឹកចេកបាត និងសងខាងដែលមានកំរាស់ ២-៣ ធឹង ការពារការប៉ះទង្គិចដល់ផ្លែ នាំឱ្យខូចគុណភាព

- ត្រូវតំរៀបផ្លែត្រប់ឱ្យមានសណ្តាប់ធ្នាប់ល្អ គឺដាក់ក្បាលជល់គ្នា ដើម្បីកុំឱ្យទងវាជង់គ្នា ធ្វើឱ្យខូចផ្លែ។ តំរៀបក្បាលចូលខាងក្នុងនៃបណ្តោយកន្ត្រកជាល ហើយយកក្បាលនៃផ្លែមួយទៀតដាក់កណ្តាលផ្លែជាបន្តបន្ទាប់
- ពេលដឹកជញ្ជូនត្រូវដាក់ទ្រុង កញ្ជេ ជាល កុំឱ្យគរលើគ្នា ធ្វើយ៉ាងណាឱ្យមានជាថ្នាក់ៗ។





## ៤) ការស្តុកទុក

ការស្តុកទុកផលិតផលត្រប់នេះ គេសង្កេតឃើញមាន :

- ទុកក្នុងម្លប់ដើមឈើ ក្រោមផ្ទះ និងរោងចាំចំការដែលមានអាកាសធាតុត្រជាក់ល្អ
- ត្រូវដាក់ពង្រាយផ្លែត្រប់ឱ្យស្តើងល្មម (កុំគរលើគ្នាក្រាស់ពេក) នាំឱ្យឆាប់រលួយបាន
- ត្រូវគ្របក្រណាត់សើម ឬបាវពីលើបើទុកមួយថ្ងៃឧស្សាហ៍ ប្រោះទឹកថែម
- ម្យ៉ាងទៀតយើងឧស្សាហ៍ ជ្រលក់ទឹកត្រជាក់ ក្នុងមួយថ្ងៃ ពីរ ទៅបី ម្តង ក្នុងករណីនេះ យើងអាចរក្សាត្រប់ទុកបាន ៤-៥ ថ្ងៃ។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

សួន សុគុន

# វិធីសាស្ត្រគ្រប់គ្រង
# ផ្លែត្រប់
## ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) **ការប្រមូលផល** :

ដំណាំល្ហុងតែងចាប់ផ្ដើមឱ្យផល បន្ទាប់ពីដាំបាន ៦ ទៅ ៧ ខែ ហើយអាចប្រមូលផលបាន ស្ទើរតែពេញមួយឆ្នាំ។ ល្ហុងឱ្យផលល្អចាប់ពីអាយុ ១ ទៅ ៣ ឆ្នាំ។ ជាទូទៅ គេសំគាល់វាថាល្មមនឹងប្រមូលផលបាន គឺមានពីរករណី :

- សំរាប់យកផ្លែខ្ចី គឺប្រមូលបានគ្រប់ពេលដែលផ្លែវាធំល្មមអាចបេះបាន
- សំរាប់យកផ្លែទុំ គឺប្រមូលបាននៅពេលផ្លែធំចាស់ និងសំបកឡើងពណ៌ (ស្រគាល) លឿងព្រឿង ជៀសវាងការទុំពេកនៅលើដើម ពីព្រោះវាអាចរងការបំផ្លាញរបស់ដង្កូវរុយ ឬនាំឱ្យវាឆាប់រលួយ។



- ពេលវេលាដែលត្រូវបេះ គឺចាប់ពីម៉ោង ៩ ព្រឹក ដល់ ៣ រសៀល ព្រោះវាមានជាតិជ័រតិច
- ដើម្បីការពារកុំឱ្យប្រឡាក់ផ្លែល្ហុង គឺយើងជៀសវាងដាក់វាឱ្យប៉ះផ្ទាល់ដីបន្ទាប់ពីបេះរួច។
- ការប្រមូលផល គឺធ្វើដោយដៃ ឬកន្ត្រកដងវែង ហើយអាចប្រមូលបានគ្រប់ពេល លើកលែងពេលភ្លៀង ដែលពិបាកនឹងបេះ។ ពេលបេះហើយត្រូវបញ្ឈរក្បាលចុះក្រោម ដើម្បីកុំឱ្យវាប្រឡាក់ជ័រ។



## ២) **ការសំអាត**

ក្រោយពីប្រមូលផលពីដើមរួច យើងត្រូវដឹកជញ្ជូនផ្លែមកផ្ទះ ហើយតំរៀបថ្នមៗលើគ្រែ ឬកញ្ជែដែលមានទ្រាប់ស្លឹកចេកស្រស់ ចំបើង ឬក្រណាត់ទន់ រួចពិនិត្យមើលផ្លែល្ហុងណាមានចៃ ឬប្រឡាក់នៅលើផ្លែ យើងត្រូវសំអាតដោយប្រើទឹកកំបោរលាង ឬយកក្រមារសើមជូតសំអាត។ យើងប្រើកំបោរ ២ ស្លាបព្រាបាយលាយជាមួយទឹក ២០ លីត្រ គឺលាងនៅពេលដែលវាប្រឡាក់ប៉ុណ្ណោះ។



## ៣) **ការជ្រើសរើស**

ជាទូទៅ យើងត្រូវជ្រើសរើសល្ហុងជាបីប្រភេទផ្សេងគ្នា។ ប្រភេទលេខ ១ គឺផ្លែណាដែលធំ ហើយមានពណ៌រលោងក្រមៅ ហើយមានលេចចេញសណ្ដង់ទុំពណ៌លឿងព្រឿងៗ និងពុំមានសត្វអុជ ឬស្នាម។ ផ្លែល្ហុងដែលចាត់ទុកជាប្រភេទលេខ ២ គឺមានទំងន់ល្មម ហើយមិនមានសត្វស៊ី ឬស្នាមរលួយ។ ចំពោះផ្លែល្ហុងប្រភេទលេខ ៣ វិញ គឺផ្លែដែលសល់ពីការជ្រើសរើសប្រភេទលេខ ១ និងលេខ ២ រួច។ ចំពោះផ្លែប្រភេទនេះ យើងអាចហូប ឬយកទៅទីផ្សារភ្លាមៗ។

## ៤) **ការបន្ទុំ**

យើងអាចដាក់វាបន្ទុំនៅក្នុងពាងធំ ដោយប្រើប្រាស់ធូប ស្លឹកឈើដើម្បីបន្ទុំវា ឬយើងអាចប្រើប្រាស់ថ្មស្ពាយដើម្បីបន្ទុំវាក៏បាន ដើម្បីឱ្យវាទុំស្មើគ្នា តែធ្វើយ៉ាងណាកុំឱ្យផ្លែល្ហុងប៉ះជាមួយថ្មស្ពាយ។ នៅពេលបន្ទុំត្រូវជ្រើសរើសយកផ្លែដែលចាស់ល្អដើម្បីបន្ទុំ ព្រោះវាអាចធ្វើឱ្យល្ហុងមានរសជាតិផ្អែម។



## ៥) ការវេចខ្ចប់ និងដឹកជញ្ជូន

ក្រោយពីធ្វើការជ្រើសរើសរួចមក យើងយកផ្លែប្រភេទលេខ ១ និងលេខ ២ រុំក្រដាសកាសែតដាក់ចូលក្នុងកញ្ជេ ដោយមានរុំស្លឹកចេក បាវ ឬក្រដាស ព័ទ្ធជុំវិញ និងចន្លោះផ្លែ រួចដឹកវាយកទៅទីផ្សារតែម្តង។ ក្នុងការដឹកជញ្ជូន គឺត្រូវដាក់តំរៀបគ្នាក្នុងរថយន្តជាថ្នាក់ៗ ឬរ៉ឺម៉កម៉ូតូ ដោយមានគំរបការពារកំដៅ និងធូលី ហើយជៀសវាងការដាក់គរលើគ្នា។ ចំពោះការដឹកជញ្ជូនផ្លូវឆ្ងាយ ត្រូវយកផ្លែល្ហុងដែលចាស់។ ធ្វើយ៉ាងណាដើម្បីឱ្យមានខ្យល់ចេញចូលល្អ ដែលអាចការពារដល់ការខូចខាតបាន ជាពិសេសចំពោះការដឹកជញ្ជូនផ្លូវឆ្ងាយ។ សូមកុំដាក់កញ្ជេគរលើគ្នាពេលដឹកជញ្ជូន ហើយគ្របកញ្ជេនឹងក្រណាត់សើមដើម្បីជៀសវាងការប្រឡាក់ធូលី និងការពារកំដៅ។









## ៦) ការរក្សាទុក

ចំពោះផ្លែល្ហុង យើងអាចរក្សាទុកដោយសំដិល ឬតំរៀបទុកនៅកន្លែងម្លប់ មានខ្យល់ចេញចូលល្អ តែមិនឱ្យប៉ះទឹកឡើយ បើពុំដូចនោះទេ ផ្លែល្ហុងនឹងឆាប់ស្អុយរលួយបាន ឬទុំមិនពេញលក្ខណៈ។ ការរក្សាទុកមុនពេលបន្ទុំ យើងអាចសំដិលនៅលើគ្រែ ឬចង្ក្រង។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

នូ សន និង មាន រ៉ា

# វិធីសាស្ត្រគ្រប់គ្រង
# ផ្លែល្ហុង
## ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction



ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

បន្លែខាត់ណាឈើ គឺជាប្រភេទបន្លែដែលពិបាកគ្រប់គ្រងណាស់ ព្រោះវាស្រួយ និងងាយរលួយ តែដើម្បីប្រមូលវាឱ្យបានល្អ ត្រូវយកចិត្តទុកដាក់ ដូចជាៈ

- ការប្រមូលផលខាត់ណាឈើ ធ្វើឡើងក្រោយពីដាំបានរយៈពេលពី ២ ទៅ ២ ខែកន្លះ
- យើងសំគាល់ឃើញដើម និងស្លឹករបស់វាឡើងម្យ៉ៅ ឬដើមមេមួយៗ ចាប់មានក្របួចផ្កា
- ការប្រមូលផលធ្វើនៅពេលអាកាសធាតុត្រជាក់ ហើយស្ងួតទឹកសន្សើមល្អពីម៉ោង ៩ ព្រឹក ដល់ម៉ោង ៣ ល្ងាច
- នៅពេលកាត់ យើងត្រូវប្រើកូនកាំបិតស្លាតូចៗ ដែលមុតល្អ និងមុខកាត់ស្មើល្អ ដើម្បីកុំឱ្យពិបាកតីមទៀត



- ជៀសវាងការដាក់ខាត់ណានៅលើដី និងក្រោមកំដៅថ្ងៃ ព្រោះវាងាយធ្វើឱ្យខាត់ណារលួយ
- ជំងឺ និងផ្សិតងាយកកើតឡើងយ៉ាងឆាប់រហ័ស នៅពេលដែលយើងកាត់ខាត់ណាបន្ទាប់ពីមានភ្លៀងធ្លាក់ភ្លាមៗ
- មុនពេលកាត់ត្រូវបង្អត់ទឹកវារយៈពេលមួយថ្ងៃ ដើម្បីកុំឱ្យវាបៀមទឹក ឬស្រូបទឹក ហើយមិនអាចឱ្យវារក្សាទុកបានយូរទេ។

## ២) ការសំអាត ប្តុំរីច

- ការតីម និងសំអាតត្រូវធ្វើឡើងភ្លាមៗ ក្រោយពីកាត់រួច ដោយកាត់ស្លឹកចាស់ ឬខូចចោល និងតីមគល់ណាដែលមិនស្មើ
- សំដិលវារយៈពេលពី ២០ ទៅ ៣០ នាទី ដើម្បីឱ្យវាស្រពាប់បន្តិច
- បន្ទាប់មកជញ្ជូនវាទៅដាក់ក្នុងម្លប់ដែលត្រជាក់ល្អ។



## ៣) ការជ្រើសរើស

- ក្រោយពីជញ្ជូនវាដាក់ម្លប់ គឺយើងត្រូវជ្រើសរើសដាក់តាមប្រភេទលេខ ១ លេខ ២ និងលេខ ៣
- ធ្វើការតំរៀបជាដុំតូចៗ (អ៊ិក) យកល្អកុំរៀបវាច្រើនពេក គឺចាប់មួយរង្វង់ដៃពីរ លើសពីនេះនាំឱ្យប្រើកំលាំងសង្កត់ទៅលើវាខ្លាំង នៅពេលដែលតំរៀបវាដាក់ក្នុងកញ្ចេ។



## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

- ក្រោយពីបានរៀបជាដុំតូចៗ (អ៊ិក) រួចមក យើងអាចតំរៀបចូលទៅក្នុងកញ្ចេ ដោយមានស្លឹកចេកស្រស់ ឬបាវព័ទ្ធជុំវិញ
- ក្នុងការរៀប ធ្វើយ៉ាងណាឱ្យក្បាលរបស់វាតងលើគ្នា ដោយមានគំលាតពី ១ ទៅ ១ តឹកកន្លះ យោងទៅតាមដើមបន្លែតូច ឬធំ

- រៀបជាស្រទាប់ៗ ដោយជៀសវាងការសង្កត់ពីលើវាខ្លាំង ដែលនាំឱ្យបែក ឬជាំខូចគុណភាព និងឆាប់រលួយ
- ក្នុងមួយកញ្ជេមានចំណុះពី ១៨០-២០០ គីឡូក្រាម បើអាចគួរប្រើចំណុះតិចជាងនេះទើបល្អ



- ការដឹកជញ្ជូន គួរដឹកដោយឡាន ឬទូក ដោយមានគ្របដំបូលត្រជាក់ ហើយកុំដាក់កញ្ជេគរលើគ្នា
- រៀបបញ្ចូលក្នុងឡាន ឬទូកដោយថ្នាក់ៗ។

## ៥) ការស្តុកទុក

ជាធម្មតាការស្តុកទុកខាត់ណាឈើ មានការលំបាកណាស់ តែតាមរយៈការសាកល្បងកន្លងមក ឃើញថាអាចរក្សាទុករហូតដល់ ៦ ថ្ងៃ។ តែការរក្សាទុកនេះ ត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួន ដូចជា :

- កាត់វាពេលអាកាសធាតុត្រជាក់ ហើយស្ងួតសន្សើម កាត់ភ្លាមត្រូវលាបសាច់ជូរ ឬកំបោរលើមុខកាត់ភ្លាម

ដើម្បីកុំឱ្យវាចេញជ័រច្រើនពេក រួចយកវាទៅដាក់ក្នុងរោងស្តុកទុក ឬក្រោមផ្ទះ ដោយយកក្រណាត់សើមហុំជុំវិញ តែមិនឱ្យប៉ះលើបន្លែឡើយ។ ក្នុងករណីនេះយកល្អគឺធ្វើយ៉ាងណាឱ្យក្រណាត់នោះសើមជានិច្ច។ តាមបទពិសោធន៍កន្លងមក ត្រូវយកចានដែក ឬធុងដែលមានទឹកពេញមកដាក់លើធ្នើរ រួចគ្របក្រណាត់ធ្នើរបៀបនេះ គឺទឹកជ្រាបចូល ធ្វើឱ្យក្រណាត់សើមជានិច្ច ដែលអាចធ្វើឱ្យបន្លែនៅស្រស់ជានិច្ច។



ការលាបកំបោរដើម្បីរក្សាទុក

---

កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង

ឌុល វណ្ណនី វុធ វណ្ណនី និង ប្រាក់ វ៉ា

# វិធីសាស្ត្រគ្រប់គ្រង ខាត់ណាឈើ ក្រោយពេលប្រមូលផល



katnal




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

IIRR
វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction



ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

- ការប្រមូលផលធ្វើឡើង ក្រោយពីដាំបានរយៈពេលពី ៣០-៣៥ ថ្ងៃ ក្រោយពីសំគាល់ឃើញគុម្ពវាឡើងជែងហែនរង ( ប្រវែងប្រហែល ២០ ស.ម )
- ជាទូទៅយើងគួរដកវានៅម៉ោង ៨ ព្រឹក និងម៉ោង ៣ ល្ងាច ពេលអាកាសធាតុត្រជាក់ល្មមដែលមិនបង្កឱ្យបន្លែស្វិតលឿនពេក តែមិនធ្វើពេលបន្លែនៅមានទឹកសន្សើមឡើយ
- ការប្រមូលផលយើងគួរប្រើចបចក់ ( ចបតូចមុខស្ដើង) ដោយចាក់ផ្ដាច់ឫសពី ២ ទៅ ៣ ធឹងពីគល់ ដែលងាយស្រួលក្នុងការប្រមូល មិនប៉ះទង្គិចខ្លាំង ហើយមិនពិបាកក្នុងការលាងទឹកទៀតផង



- ប្រយ័ត្នកុំឱ្យប៉ះទង្គិចខ្លាំងលើស្លឹក ឬធាងរបស់វាដើម្បីជៀសវាងការបាក់ ឬជាំ
- កាត់បន្ថយការប៉ះកំដៅផ្ទាល់ និងការប៉ះដី ព្រោះវាអាចធ្វើឱ្យសាលាដ៏ឆាប់ជាំ និងងាយឆ្លងមេរោគ
- ជំងឺផ្សិតអាចកកើតឡើងភ្លាមៗ នៅពេលដែលយើងប្រមូលផលភ្លាមៗ បន្ទាប់ពីមានភ្លៀងធ្លាក់
- មុននឹងប្រមូលផល ១ ថ្ងៃ មិនត្រូវស្រោចទឹកទេ។



## ២) ការសំអាត

- ប្រើកូនកាំបិតមុតកាត់រីមឫសដែលសល់ និងស្លឹកមិនល្អចេញ ដើម្បីការពារក្នុងការឆ្លងទៅបន្លែដែលល្អ
- ប្រសិនបើសាលាដ៏មិនប្រឡាក់ដីទេ គឺមិនចាំបាច់លាងទឹកទេ។ មិនត្រូវលាងទឹកត្រជាក់ជាមួយស្លឹកសាលាដ៏ទេ ព្រោះអាចធ្វើឱ្យវាស្រូបទឹក និងងាយឆាប់រលួយ
- ប្រើទឹកស្អាតដើម្បីលាងវា ហើយឧស្សាហ៍ផ្លាស់ប្ដូរ បើពុំដូច្នេះទេវាអាចឆ្លងមេរោគតាមរយៈទឹកបាន
- យកវាសំដិលក្នុងម្លប់ឱ្យស្រស់ទឹក ទើបយកទៅបញ្ចូលក្នុងកញ្ជេ
- តំរៀបជាអ៊ិក ( តំរៀបជាដុំៗ) ដោយធ្វើយ៉ាងណាឱ្យគល់របស់វាស្មើល្អ។ ម្យ៉ាងទៀត យើងអាចយកស្លឹកចេក ឬស្លឹកឈូកមករុំវាដើម្បីឱ្យស្រស់បានយូរ។



## ៣) ការវេចខ្ចប់ និងដឹកជញ្ជូន

- តំរៀបវាក្នុងកញ្ជេ ឬអង្រើងដែលមានទំងន់ពី ៣០ ទៅ ៥០ គ.ក្រ ដោយមានហ៊ុំស្លឹកចេកជុំវិញ ដើម្បីការពាររំហួត និងធូលីដី
- តំរៀបវាជាជួរៗ ដោយរក្សាឱ្យមានចន្លោះខ្យល់ចេញចូលល្អ ដើម្បីជៀសវាងការឆាប់រលួយ
- ការវេចខ្ចប់ និងដឹកជញ្ជូនធ្វើយ៉ាងណាកុំឱ្យសង្កត់លើគ្នាខ្លាំង ដើម្បីកាត់បន្ថយការបាក់បែក និងការបញ្ចេញ

សារធាតុអេទីឡែនដែលបណ្តាលឱ្យស្លឹកបន្លែឡើងពណ៌ក្រហម ។ ការធ្វើរបៀបនេះទើបអាចរក្សាពណ៌សម្បុរ និងគុណភាពបានល្អ

- ការដឹកជញ្ជូនត្រូវធ្វើឡើងនៅពេលត្រជាក់ (ពីម៉ោង ៥ ល្ងាច ដល់ម៉ោង ៧ ព្រឹក)
- ពេលដឹកជញ្ជូនត្រូវគ្របក្រណាត់សើមការពារកញ្ចែ ។







## ៤) ការស្តុកទុក

- សាលាដស៊ិត ជាទូទៅគេពុំរក្សាវាទុកយូរថ្ងៃទេ ពីព្រោះវាអាចបណ្តាលឱ្យខូចគុណភាព ដោយរសជាតិថយចុះ

តែរក្សាទុកវិញ ត្រូវរកកន្លែងដែលត្រជាក់ ហើយមានខ្យល់ចេញចូលល្អ

- ប្រើក្រណាត់ ឬបាវសើមហ៊ុំព័ទ្ធជុំវិញ តែកុំឱ្យប៉ះវាផ្ទាល់ដើម្បីការពាររំហួត
- ឧស្សាហ៍ប្រោះទឹកវា ដើម្បីកុំឱ្យវាស្រពោនហួសគំរិត
- ធ្វើតាមរបៀបខាងលើអាចរក្សាទុកបានពី ៤-៥ ថ្ងៃ ដោយមានរសជាតិដដែល ។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

សឿន ចក់ ប្រាក់ រ៉ា និង បែអេ ព៉ត់

# ទិធីសាស្ត្រគ្រប់គ្រង
# សាលាដ៏ស៊ិត
## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
CEDAC
Centre d'Etude et de Développement Agricole Cambodgien

IIRR
វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

យើងអាចប្រមូលផលប៉េងប៉ោះបាននៅអាយុ ២ ខែក្រោយពីដាំ។ ការប្រមូលផលធ្វើឡើងជាច្រើនសា (គឺអាចពី ៨ ទៅ ១០ ដង បណ្ដោក់គ្នា)។ ការប្រមូលផលម្ដងៗ មានចន្លោះពី ២ ទៅ ៣ ថ្ងៃ។ ក្នុងការប្រមូលផល យើងអាចបេះដោយដៃ តែយកល្អត្រូវយកកន្ត្រៃ ឬកូនកាំបិតស្លាទៅកាត់ ហើយធ្វើយ៉ាងណាកុំឱ្យប៉ះផ្លែ និងដើម។ យើងអាចប្រមូលផលប៉េងប៉ោះ នៅពេលអាកាសធាតុត្រជាក់ ប៉ុន្តែបន្ទាប់ពីស្ងួតសន្សើមអស់។ ទឹកសន្សើមបណ្ដាលឱ្យងាយកកើតមេរោគនៅលើផ្លែប៉េងប៉ោះ ចំណែកកំដៅងាយធ្វើឱ្យផ្លែប៉េងប៉ោះឆាប់ទុំ។ ការប្រមូលផល គួរធ្វើឡើងនៅពេលរសៀលចាប់ពីម៉ោង ៣:០០ ដល់ម៉ោង ៥:០០ ល្ងាច។ ពីព្រោះក្នុងរយៈពេលនេះផ្លែប៉េងប៉ោះស្រស់ទឹកល្អ និងមានភាពរឹងមាំ។





## ២) ការសំអាត និងជ្រើសរើស

ប្រសិនបើមិនអាចជៀសវាងបានក្នុងការប្រមូលផលនៅពេលភ្លៀង យើងត្រូវលាងទឹកវា ហើយសំដិលឱ្យស្ងួតមុននឹងធ្វើការវេចខ្ចប់។ ជាទូទៅ យើងមិនចាំបាច់ធ្វើការលាងទឹកផ្លែប៉េងប៉ោះទេ។ ប៉ុន្តែប្រសិនបើផ្លែវាមានប្រឡាក់ដី យើងត្រូវលាងវា ហើយសំដិលឱ្យស្ងួត។ មុនពេលលាងទឹកត្រូវដកយកផ្លែដែលស្អុយចេញ ព្រោះវាអាចឆ្លងដល់ផ្លែដទៃទៀត។

ជាទូទៅ យើងសំអាតប៉េងប៉ោះ ឬជ្រើសរើសឡើងក្រោយពីប្រមូលផលពីដើមរួច។ យើងយកវាមកសំដិលនៅទីម្លប់រយៈពេលពី ១៥-២០ នាទី ទើបជ្រើសរើសវាតាមប្រភេទលេខ ១ លេខ ២ និងលេខ ៣ ក្រៅពីនោះជាចំណាត់ថ្នាក់លេខ ៤ ដោយដាក់តាមចំណាស់របស់វា ទុំដាក់ដោយទុំ និងចាស់ដាក់ដោយចាស់ ដកផ្លែដែលស្អុយចេញ។



## ៣) ការវេចខ្ចប់ និងដឹកជញ្ជូន

ក្នុងការវេចខ្ចប់ចំពោះប៉េងប៉ោះ គឺក្រោយពីសំដិលរយៈពេល ១៥-២០ នាទីរួចមក យើងអាចរៀបដាក់ក្នុងកញ្ជេតែម្ដង។ តែចំពោះកញ្ជេត្រូវយកបាវ ឬស្លឹកចេកស្រស់ដាក់ពីខាងក្នុង ដើម្បីកុំឱ្យប៉េងប៉ោះទង្គិចផ្ទាល់ជាមួយឬស្សី ឬដែកកញ្ជេនោះ។ នៅពេលវេចខ្ចប់ យើងអាចអង្រួនកញ្ជេបន្តិចៗ ដើម្បីឱ្យប៉េងប៉ោះណែននៅក្នុងកញ្ជេ ជៀសវាងរលាក់នៅពេលដឹកជញ្ជូនធ្វើឱ្យវាខូចផ្លែ។ ដើម្បីឱ្យ វាណែនល្អ គឺយើងដាក់ផ្លែប៉េងប៉ោះបានជិតពាក់កណ្ដាលកញ្ជេ យើង ធ្វើការអង្រួនម្ដង ហើយធ្វើ ការអង្រួនរបៀបនេះ ជាបន្តបន្ទាប់រហូតដល់យើងដាក់ផ្លែប៉េងប៉ោះពេញ ក្នុងកញ្ជេ។ យើងយកវាទៅដាក់លើម៉ូតូ រ៉ឺម៉ក ឬឡានដឹកមកទីផ្សារ តែយើងត្រូវតំរៀបជាថ្នាក់ៗ ជៀសវាងការដាក់គរលើគ្នា។ ការដឹកជញ្ជូនត្រូវមានគំរបការពារកំដៅ និង ធូលី។



## ៤) ការរក្សាទុក

ជាធម្មតា យើងអាចរក្សាទុកប៉េងប៉ោះបានរយៈពេល ១ អាទិត្យ ដោយគ្រាន់តែរក្សាវានៅកន្លែង

សមស្របមួយ ត្រជាក់ហើយមានខ្យល់ចេញចូលល្អ ដោយយកក្រណាត់ ឬបាវសើមគ្រប ឬហ៊ុំវាជុំវិញ ហើយឧស្សាហ៍ប្រោះទឹក។ ផ្សេងពីនេះទៀត យើងអាចរក្សាប៉េងប៉ោះបានរហូតដល់១០ ទៅ ១៥ ថ្ងៃ ដោយប្រើវិធីដូចខាងក្រោម :

- អាចម៍រណារម៉ដ្ឋ (ចំនួន ១ គីឡូក្រាម ទឹកអូសាវ៉ែល ចំនួន ១ គំរបដប (គំរបដបអូសាវ៉ែល) ទឹកធម្មតា ចំនួន ១ លីត្រ ដាក់លាយគ្នាក្នុងចានដែក ឬធុងផ្សេងៗ សមាមាត្រនេះគឺសំរាប់រក្សាទុកផ្លែប៉េងប៉ោះ១ គ.ក្រ។




**សំភារៈសំរាប់រក្សាទុកផ្លែប៉េងប៉ោះ**

**របៀបថែរក្សាទុក** : ក្នុងការថែរក្សាទុកប៉េងប៉ោះ យើងត្រូវអនុវត្តទៅតាមដំណាក់កាលបន្តបន្ទាប់ដូចខាងក្រោម :

- ចាក់ទឹកធម្មតាលាយជាមួយទឹកអូសាវ៉ែល (តាមកំរិតខាងលើ) កូរចូលគ្នាឱ្យសព្វ ហើយយកផ្លែប៉េងប៉ោះលាងក្នុងទឹកសូលុយស្យុងនេះ ដើម្បីសំលាប់មេរោគ។ បន្ទាប់មក ស្រង់ប៉េងប៉ោះទុកមួយកន្លែងឱ្យស្រស់ទឹកសិន។

- យកទឹកល្បាយអូសាវ៉ែលនេះលាយជាមួយអាចម៍រណារឱ្យសើមល្មម ជៀសវាងកុំឱ្យសើមពេក រួចយកផ្លែប៉េងប៉ោះមកដាក់តំរៀបគ្នានៅក្នុងចានដែក ដែលមានដាក់អាចម៍រណារនោះ ដោយដាក់ផ្នែកខាងក្បាលឡើងលើ។ ក្នុងការតំរៀបនេះ ជៀសវាងកុំឱ្យផ្លែប៉េងប៉ោះប៉ះគ្នា។

**របៀបរៀបប៉េងប៉ោះរក្សាទុក ដោយដាក់ផ្នែកខាងក្បាលនៅលើ**

- បន្ទាប់មក យើងរោយអាចម៍រណារគ្របពីលើផ្លែប៉េងប៉ោះ។ យើងអាចតំរៀបផ្លែប៉េងប៉ោះជាច្រើនស្រទាប់ៗ តាមរបៀបដូចខាងលើរហូតអស់

- បន្ទាប់ពីរៀបចំស្រេចហើយ ត្រូវយកវាទៅទុកនៅកន្លែងមួយល្អត្រឹមត្រូវ ផុតពីដៃក្មេង រហូតដល់យើងត្រូវការយកវាមកធ្វើជាអាហារ ឬលក់ រហូតដល់រយៈពេល ១៥ ថ្ងៃ។

---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

សួន សុផល និង ធុល វណ្ណនី

# វិធីសាស្ត្រគ្រប់គ្រង
# ផ្លែប៉េងប៉ោះ
## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) បច្ចេកទេសនៃការប្រមូលផល

ជាធម្មតា គេអាចប្រមូលផលខ្ទឹមបារាំងនៅពេលដែលវាមានអាយុពី ៣ ទៅ ៤ ខែក្រោយពីដាំ ហើយនៅពេលយើងសង្កេតឃើញថាដើម (ស្លឹក ៥០-៧៥%) របស់វាត្រង់កន្លែងក្បែរមើមទន់បាក់ក។ តែបើស្លឹករបស់វា (ដើម) នៅត្រង់ យើងមិនអាចប្រមូលផលបានទេ ព្រោះខណៈពេលនេះខ្ទឹមបារាំងនៅមានជាតិទឹកច្រើន ដែលធ្វើឱ្យឆាប់រលួយ ឬខូច។

- ប្រមូលផលដោយដៃ ឬចបចក់ ប្រសិនបើដីរឹង
- ប្រមូលផលនៅពេលស្ងួតទឹកសន្សើម និងគ្មានភ្លៀង
- ត្រូវបង្អត់ទឹករយៈពេល ២-៣ សប្តាហ៍មុនពេលប្រមូលផលដើម្បីឱ្យវារក្សាទុកបានយូរ
- យើងអាចបំបែកមើមខ្ទឹមប្រសិនបើវាមានលើសពី ១។



## ២) ការសំអាតក្រោយពេលប្រមូលផល

- ក្រោយពីដកប្រមូលផលរួច ត្រូវកាត់ដើមរបស់វាចេញ ដោយរក្សាទុកទងមើមប្រហែល ៥ ធឹង ឬ ៣ ធ្នាប់ដៃ
- ក្រោយពេលប្រមូលផលហើយ មិនត្រូវយកមើមទៅលាងទឹកទេ ត្រូវទុកទាំងជាប់ដីតិច១ ហើយកាត់ឫសចេញខ្លះ (ដោយប្រើកាំបិត ឬកន្ត្រៃ) តែលៃយ៉ាងណាកុំឱ្យកាត់ទៅដល់គល់ឫស បើយើងកាត់ដល់គល់ឫសការរក្សាទុកក៏មិនបានយូរដែរ វាឆាប់រលួយមើម ដោយខ្សោះជាតិទឹក និងការឆ្លងមេរោគ។



## ៣) ការជ្រើសរើសមើម

ក្រោយពេលសំអាត យើងត្រូវជ្រើសរើសមើមណាដែលល្អទុកមួយដុំ ចំពោះមើមណាដែលកាត់ហើយមានជាប់ដើម (បណ្តូលស្លឹក) ដែលមានពណ៌លឿង ឬមើមណាដែលចង់រលួយ ជាពិសេសយើងសង្កេតឃើញថាមិនសូវល្អត្រូវជ្រើសរើសដាក់មួយដុំ ដើម្បីបញ្ចេញលក់ឱ្យទាន់ពេលវេលា។ ព្រោះបើសិនជាយើងមិនបានជ្រើសរើស ហើយរក្សាទុកវាលាយគ្នា នាំឱ្យខូចគុណភាពដល់មើមដែលល្អទៀត ដោយសារការឆ្លងគ្នា។ ក្នុងករណីនេះ យើងជ្រើសរើសមើមជា ៤ ប្រភេទផ្សេងគ្នា :

- ប្រភេទលេខ ១ មានមើមធំថ្លោស ហើយមានគុណភាពល្អ
- ប្រភេទលេខ ២ ទំហំកណ្តាល និងមានគុណភាពល្អ
- ប្រភេទលេខ ៣ ដែលតូចជាងគេ និង
- ប្រភេទលេខ ៤ ជាប្រភេទមើមដែលមានការប៉ះទង្គិច ឬខូចទ្រង់ទ្រាយណាមួយ ដូចចំណុចខាងលើ។



## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

ការវេចខ្ចប់ និងដឹកជញ្ជូនមើមខ្ទឹមបារាំង មាន ២ ករណី :

- ករណីទី ១ : ធ្វើឡើងក្រោយពេលប្រមូលផលហើយភ្លាម ក្រោយពីសំអាត និងជ្រើសរើសរួចត្រូវយកជាលឬកញ្ចេដោយមានទ្រាប់ជុំវិញ ដូចជាស្លឹកចេកស្រស់ ឬបាវដែលមានសារធាតុទន់ ហើយអាចទប់កុំឱ្យវាប៉ះទង្គិចខ្លាំង។ ការដឹកជញ្ជូនត្រូវតំរៀបជាថ្នាក់១ ជៀសការ

ការដាក់សង្កត់លើគ្នានាំឱ្យបែក ឬជាំ ព្រោះមើមរបស់វានៅស្រស់ ។

- ករណីទី ២ : ធ្វើឡើងក្រោយពីការរក្សាអស់រយៈពេលចាប់ពី ១ ខែឡើងទៅសំបកខាងក្រៅរបស់វារឹងជាងនៅស្រស់ ។ ដូច្នេះ យើងអាចប្រើកញ្ជេ ឬបាវសំណាញ់ក្នុងករណីការដឹកជញ្ជូន ចំពោះបាវសំណាញ់អាចដាក់ត្រួតលើគ្នា ២ ឬ ៣ ជាន់ក៏បាន តែជៀសវាងដាក់ត្រួតលើគ្នាច្រើនជាន់ពេក នាំឱ្យវាចេញញើស ដែលអាចធ្វើឱ្យមើមរបស់វារលួយបាន ។



## ៥) ការសង់រោងសំរាប់ស្តុកទុកមើម

ចំពោះការស្តុកទុកយើងគួរសង់រោងមួយដែលអាចទប់កំដៅបានល្អ ហើយចំហ ទ្វារសងខាងដើម្បីឱ្យមានខ្យល់ចេញចូល ។ នៅក្នុងរោងគួរមានធ្វើធ្នើរជាថ្នាក់ៗ ដោយមានរនាបឬស្សី ដែលមានខ្យល់ចេញចូលល្អ ហើយថ្នាក់ខាងក្រោមគួរមានកំពស់ ៧ តឹកពីដី ។

- ការស្តុកមើមខ្ទឹមបារាំងយើងត្រូវដាក់មើមពង្រាយជៀសវាងដាក់មើមគរលើគ្នា ហើយឧស្សាហ៍ទៅពិនិត្យមើល ប្រសិនបើមានឃើញមើមណារលួយត្រូវដកវាចេញ ព្រោះថាបើយើងមិនធ្វើដូច្នេះទេ នាំឱ្យវាឆ្លងគ្នារលួយទាំងអស់ ។
- ការរក្សាទុកយូរនេះ គឺដើម្បីឱ្យតំលៃខ្ទឹមបារាំងឡើងខ្ពស់បន្តិច ព្រោះបើយើងប្រមូលផលភ្លាមលក់ភ្លាមនាំឱ្យតំលៃខ្ទឹមថោកពេក ព្រោះរដូវប្រមូលផលខ្ទឹមស្របគ្នានាំឱ្យវាត្រូវចាល់ និងតំលៃធ្លាក់ចុះ ។
- របៀបរក្សាទុក គឺយើងអាចចងព្យួរវានៅក្រោមផ្ទះបាន ប្រសិនបើមិនមានឃ្លាំងសំរាប់រក្សាទុកទេ ។ ប៉ុន្តែយើងត្រូវពិនិត្យមើលវា ២-៣ ថ្ងៃម្តង ក្រែងមានមើមដែលស្អុយរលួយ ហើយយើងយកមើមនោះចេញ ។




---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

ឌុល វណ្ណនី និង ជាម ហៀង

# វិធីសាស្ត្រគ្រប់គ្រង
# ខ្ទឹមបារាំង
## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgier

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ការប្រមូលផលចេកពងមាន់ធ្វើឡើងក្រោយពី :

- ទំលាក់ត្រយូងអស់រយៈពេលពី ១ខែ ទៅ ១ ខែ ១០ ថ្ងៃ
- មានអាយុសមស្រប ហើយផ្លែរបស់វាលប់ជ្រុង ( មូល)
- សំបកផ្លែរបស់វាស្តើងរលោង និងមានឡើងម្សៅ
- ផ្លែរបស់វាចាប់ប្រែពណ៌ពីបៃតងទៅលឿង





- ការប្រមូលធ្វើឡើងនៅពេលស្រស់ទឹកសន្សើម ភ្លៀង ដើម្បីជៀសវាងការឆាប់ប្រេះ ឬស្អុយរលួយ
- ប្រើកាំបិតផ្គាក់មុត ដោយចាប់ផ្តើមកាប់ពាក់កណ្តាលដើម ឱ្យបាក់ដើមជិតដាច់ រួចចាប់ចុងស្ទងឱ្យជាប់ ទើបកាត់ផ្តាច់ពីដើម
- កាត់រួចត្រូវដាក់ស្ទងបញ្ឈរដោយមានបង្អែក ឬក៏ចងព្យួរវាឱ្យស្រក់ជ័រក្នុងម្លប់ ហើយត្រូវប្រយ័ត្នកុំឱ្យប៉ះទង្គិចផ្លែ ពីព្រោះវាឆាប់រលាករលួយណាស់ ។
- យើងគួរប្រមូលផលនៅម៉ោង ៩ ព្រឹក ដល់ម៉ោង ៣ រសៀល ព្រោះពេលនេះវាចេញជ័រតិច ហើយអាចកាត់បន្ថយការខូចខាតដោយសារការប្រឡាក់ជ័រ ។

## ២) ការតំរឹម និងសំអាត

- តំរឹមស្ទងឱ្យស្មើគ្នា ( ប្រវែង ១ តឹក) ជៀសវាងកុំឱ្យគល់ស្ទងនៅសល់វែងពេកពីព្រោះវាធ្ងន់ និងមានប៉ះទង្គិចលើស្ទងផ្សេងទៀត
- យកក្រណាត់ទន់ជូតសំអាតដោយថ្នមៗ បើមានប្រឡាក់ដីលើ ផ្លែ
- កាត់ផ្លែ ឬស្និតណាដែលប្រេះ ឬស្អុយចេញដើម្បីការ-ពារការឆ្លងទៅផ្លែផ្សេងទៀត ។



## ៣) ការដឹកជញ្ជូន

- ការដឹកជញ្ជូន គឺចងកាងម៉ូតូដោយប្រុងប្រយ័ត្នកុំឱ្យវាយោលប៉ះគ្នា
- ចងព្យួរក្នុងទ្រុងឡានដោយមានដង្កៀបកៀបចុង និងដើមទងកុំឱ្យវាយោលទង្គិចគ្នា
- យើងអាចប្រើប្រាស់បាវក្រដាស/ក្រចៅគ្របដើម្បីចៀសវាងការប្រឡាក់ដី ។



## ៤) ការស្តុកទុក

- ចេកពងមាន់អាចរក្សាទុកពី ៥ ទៅ ១២ ថ្ងៃ (គឺមិនឱ្យវាទុំ) ដោយគ្រាន់តែចងចុងស្ទងឡើងលើនៅកន្លែងម្លប់ត្រជាក់ ដូចជាក្រោមផ្ទះ ឬរោងសំរាប់ស្តុកតែម្តង ហើយឧស្សាហ៍ពិនិត្យមើល បើសំបកផ្លែរបស់វាស្រពាប់ត្រូវយកកូនស្បោងដាក់ទឹក ហើយចងភ្ជាប់ នៅគល់ស្ទងរបស់វា។





## ៥) ការបន្ទុំ

- មុនពេលបន្ទុំ ត្រូវរក្សាទុករយៈពេល ២ ថ្ងៃសិន ដើម្បីឱ្យស្ងិតសណ្តង់ និងកុំឱ្យវារលួយ
- ការបន្ទុំចេកពងមាន់ធ្វើឡើងទាំងស្ទងតែម្តង ដោយគ្រាន់តែយកក្រណាត់ស្តង់ ឬស្បោងប្លាស្ទិករុំវាឱ្យជិត រួចដុតធូប ឬសារធាតុដែលមានផ្សែងច្រើន ហើយមានក្លិនក្រអូប ឬក៏ប្រើថ្នស្មុយតែម្តង (គុណភាព និងក្លិនមិនល្អ)
- ម្យ៉ាងទៀត យើងអាចយកវាទៅបន្ទុំក្នុងពាងធំមួយ ដោយយកស្លឹកឈើដូចជា ទំពូង អំពិលទឹក ម្រុំ អង្គាដី។ល។ ដែលហាលថ្ងៃស្រពោនរយៈពេល ១ ម៉ោង មកដាក់ចន្លោះស្ទង ឬផ្លែរបស់វា រួចដុតធូប ៣ ទៅ ៤ សរសៃ ក្នុងរយៈពេល ២ ថ្ងៃ ចេកទុំដោយមានគុណភាពល្អ និងក្លិនក្រអូប។




---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

ញៀត វណ្ណា ពត បញ្ញារិទ្ធិ ជាម សារេត និង នេត សុខ

# វិធីសាស្ត្រគ្រប់គ្រង

# ចេកពងមាន់

## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
CEDAC
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
IIRR
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) <u>ការប្រមូលផល</u>

- ជាទូទៅ យើងប្រមូលផលស្ពៃក្តោបដោយសំគាល់ទៅលើអាយុរបស់វា គឺចាប់ពី ៣ ទៅ ៣ ខែកន្លះ បន្ទាប់ពីដាក់គ្រាប់ដល់ដី
- បន្ទាប់ពីនេះ គឺការពិនិត្យទៅលើលក្ខណៈក្តោបរបស់ស្ពៃ ដូចជាយកដៃច្របាច់ទៅលើវា បើរឹងល្អ មានន័យថាស្ពៃពេញវ័យអាចប្រមូលផលបាន ឬសំគាល់ទៅលើចុងស្លឹកស្រទាប់ក្រៅរបស់វាមូរ
- ពេលប្រមូលផល គឺធ្វើឡើងនៅពេលល្ងាចត្រជាក់ល្អពីម៉ោង ៣-៤ ដើម្បីឱ្យទឹកសនៀមស្រស់ល្អ
- ការប្រមូលផលត្រូវយកកូនកាំបិតចុងស្រួចដែលមុតល្អ កាត់វាដោយទាញក្តោបរាងផ្តេកបន្តិច រួចទើបកាត់





- ការប្រមូលផលត្រូវធ្វើឡើងនៅពេលមានអាកាសធាតុស្ងួតល្អ។ កាលណាយើងប្រមូលផលនៅពេលភ្លៀង ឬបន្ទាប់ពីភ្លៀងភ្លាមៗ នោះធ្វើឱ្យមេរោគងាយបង្កជំងឺឱ្យស្ពៃក្តោបឆាប់រលួយ។

## ២) <u>ការតំរឹម និងសំអាត</u>

- ក្រោយពីកាត់រួច យើងពុំចាំបាច់បកស្រទាប់ក្រៅចេញទេ គឺគ្រាន់តែតំរឹមឱ្យស្អាត ហើយលាបកំបោរ ភ្លាមៗ ឬសាច់ជូរនៅមុខកាត់ ដើម្បីការពារការចេញ ជ័រច្រើន ឬឆ្លងជំងឺផ្សេងៗ។ បន្ទាប់មក យកវាទៅដាក់ ក្នុងម្លប់ថ្មមៗហើយមិនដាក់គរលើគ្នាទេ ជៀសវាងកុំឱ្យជាំ
- ការសំអាត គឺយើងគ្រាន់តែកាត់សំបកបន្តិចបន្តួចបាន ហើយ រួចប្រញាប់យកវាទៅដាក់នៅកន្លែងម្លប់ត្រជាក់ ដើម្បីកុំឱ្យហួតជាតិទឹក ស្វិតស្រពោនបាត់បង់ទំងន់។





## ៣) <u>ការវេចខ្ចប់ និងដឹកជញ្ជូន</u>

- ដើម្បីឱ្យការវេចខ្ចប់ និងដឹកជញ្ជូនបានល្អ មិនបាត់បង់ យើងអាចប្រើចំបើង ក្រដាស បាវ ស្លឹកចេក ឬស្លឹកឈូកសំរាប់ធ្វើជាទ្រនាប់ ដើម្បីកាត់បន្ថយការប៉ះទង្គិច
- ឯការដឹកជញ្ជូន គួរដាក់តាមថ្នាក់ៗ ជៀសវាងការដាក់គរលើគ្នា
- ប្រសិនបើអាចធ្វើបាន យើងអាចយកក្រដាសកាសែតមកហ៊ុំលើក្តោបនិមួយៗ តែម្តង ទើបដាក់បញ្ចូលក្នុងកញ្ជេ
- ជៀសវាងការបកផាងស្រទាប់ក្រៅរបស់វាមុនពេលដាក់លក់លើស្តង់
- ពេលដឹកជញ្ជូន ត្រូវរក្សាឱ្យមានគំរបជានិច្ចដើម្បីការ-ពារកំដៅ និងធូលី។





## ៤) ការស្តុកទុក

យើងអាចស្តុកស្ពៃក្តោបដោយធ្វើការ រុំក្រដាសកាសែត ហើយយកវាទៅដាក់ ក្នុងធុងត្រដាក់/ពាងធ្វើពីដីគ្របក្រណាត់សើម ហើយ ប្រោះទឹក ១ ថ្ងៃ ២ ដង (ព្រឹក-ល្ងាច) លើក្រណាត់នោះ នៅពេលវាស្ងួត។ ជាលទ្ធផលគឺអាចរក្សាទុកបានយូររហូត ដល់ ១៦ ថ្ងៃ ដោយពុំមានស្រកទំងន់ឡើយ។





រូបភាពមុនពេលរក្សាទុក



រូបភាពក្រោយពេលរក្សាទុកបាន ១៦ ថ្ងៃ

---


**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

វុធ វណ្ណនី . ឌុល វណ្ណនី និង ជាម គីមលី


# វិធីសាស្ត្រគ្រប់គ្រង
# ស្ពៃក្តោប
## ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
CEDAC
Centre d'Etude et de Développement Agricole Cambodgien

IIRR
វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) **ការប្រមូលផល**

ដើម្បីប្រមូលផលម្រះឱ្យបានល្អ គួរយកចិត្តទុក-ដាក់លើចំណុចសំខាន់ៗ មួយចំនួនដូចខាងក្រោម :

- យើងបេះតែផ្លែណាចាស់ល្មម ឬផ្លែពេញវ័យគឺនៅពេលដែលក្រឡាវារីកហើយរលោងពណ៌បៃតងភ្លាវ
- ក្នុងការបេះ ឬកាត់ យើងគប្បីត្រូវប្រើសំភារៈដូចជា : កូនកាំបិតស្លា កន្ត្រៃមុត ដើម្បីងាយស្រួលកាត់កុំឱ្យប៉ះពាល់ដល់ដើម និងទង ដែលអាចបណ្តាលឱ្យវាងាប់ ឬមានជំងឺផ្សេងៗ
- ការកាត់ត្រូវទុកសណ្តង់ ឬទងផ្លែមួយចង្អុលដៃស្មើ ៤-៥ ធ្នឹង ដើម្បីកុំឱ្យផ្លែឆាប់ខូច
- យើងចាប់ផ្តើមកាត់ ឬបេះវាពេលព្រឹកម៉ោង ៨-១១ ពេលល្ងាចពីម៉ោង ២-៥ វាជាការងារមួយសមស្របក្នុងការប្រមូលធ្វើឱ្យផ្លែមិនងាយស្វិតស្រពោនដោយកំដៅថ្ងៃ ហើយស្រស់ទឹកល្អ
- ក្នុងការកាត់ យើងគប្បីកាត់បញ្ឆិតទង ឬសណ្តង់ ដើម្បីការពារជ័រនៅកកជាប់ទង ឬដើម ដែលអាចធ្វើឱ្យដើមទទួលនូវជំងឺផ្សេងៗ
- យើងចាប់បេះនៅពេលអាកាសធាតុល្អ ពោលគឺគ្មានភ្លៀង គ្មានទឹកសន្សើម ឬកំដៅខ្លាំងពេក។



## ២) **ការសំអាត និងការជ្រើសរើស**

ក្រោយពីបានប្រមូលរួច យើងគួរធ្វើការជ្រើសរើស និងសំអាត ដូចជា :

- ជ្រើសរើសផ្លែណាដែលស្អុយរលួយ ខ្ទិនខ្ទង់ ឬផ្លែមិនល្អចេញ
- ជ្រើសរើសផ្លែខ្ចីពេក និងចាស់ពេក ទុកន្លែងផ្សេង
- តំរឹមទុកសណ្តង់ ឬទងផ្លែតែ ៤-៥ ធ្នឹង ឬមួយចង្អុលដៃ
- ជូតសំអាតផ្លែដែលប្រឡាក់ថ្នមៗ ដោយប្រើក្រណាត់សើមទន់ ហើយប្រយ័ត្នបំផុត ជៀសវាងការប៉ះទង្គិចខ្លាំង ដែលអាចប៉ះពាល់ក្រឡារបស់វា។





## ៣) **ការវេចខ្ចប់ និងការដឹកជញ្ជូន**

ចំណុចមួយចំនួន ដើម្បីវេចខ្ចប់ឱ្យបានល្អ មាន :

- យើងគួរទុកទាំងក្រដាសរុំផ្លែ ដើម្បីជួយទប់ទល់ការជាំខូច និងកុំឱ្យប្រឡាក់ជ័រពីផ្លែផ្សេងទៀត
- ក្រោយពីខ្ចប់ក្រដាសរួចហើយ យកម្រះនេះដាក់ក្នុងកន្ត្រក កញ្ជេ ជាល ឬទ្រុងដែក ក្រោយពេលទុកសំដិលឱ្យវាត្រជាក់ ២០-៣០ នាទីរួចមក
- ចំពោះ ជាល កន្ត្រក ឬទ្រុងដែកនោះ ត្រូវក្រាល

ដោយស្លឹកចេក ឬបាវកំរាស់ប្រមាណពី ២-៣ ផឹង ហើយសងខាងទ្រុងក៏ត្រូវហ៊ុំព័ទ្ធដែរ ដើម្បីការពារការប៉ះទង្គិចគ្នាក្នុងពេលដឹកទៅកាន់ទីផ្សារ

- យើងតំរៀបវាក្នុងកញ្ជេ ឬជាល ដោយយកផ្លែ ឬក្បាលនៃផ្លែមួយដាក់ពីលើពាក់កណ្ដាលនៃផ្លែ មួយទៀត
- ត្រូវដាក់កញ្ជេ ឬជាល ជាថ្នាក់ៗ ចំណែកឯកញ្ជេរ ឬជាល ត្រូវគ្របក្រមាសើម ឬស្លឹកចេកពីលើការពារកំដៅ និងធូលី ។
- ធ្វើយ៉ាងណាកុំឱ្យវាហួសមាត់កញ្ជេនាំឱ្យពិបាកដាក់បញ្ចូលឡាន និងប៉ះទង្គិច ។



៤) **ការស្តុកទុក**

ដើម្បីទុកដាក់ផលិតផលម្រះឱ្យបានសមស្រប ហើយបានយូរ យើងអាចធ្វើដូចខាងក្រោម :

- យើងគប្បីទុកដាក់នៅក្នុងម្លប់ក្រោមផ្ទះ លើផ្ទះ ឬកន្លែងរោងចាំចំការ ហើយមានខ្យល់ត្រជាក់
- ត្រូវតំរៀបឱ្យបានស្តើងល្មម ដើម្បីកុំឱ្យវាសង្កត់លើគ្នា
- មិនត្រូវប៉ះពាល់វានៅពេលទុកនេះឡើយ
- ត្រូវយកក្រមា ឬក្រណាត់សើមគ្របពីលើ ដើម្បីឱ្យវានៅស្រស់ល្អ ក្នុងករណីនេះ គេអាចរក្សាទុកវាបាន ២-៣ ថ្ងៃ ។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

វុធ វណ្ណនី និង ហុក ឆេង

# ទិធីសាស្ត្រគ្រប់គ្រង
# ផ្លែម្រះ
## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ជាទូទៅការ៉ុតមានរយៈពេលលូតលាស់ ៣ ទៅ ៣ ខែកន្លះ នៅរដូវវស្សា បើរដូវប្រាំងអាចមានរយៈពេល ដល់ ៤ ខែ ទើបអាចប្រមូលផលបាន។

- ការប្រមូលផល ជាដំបូងយើងត្រូវពិនិត្យទៅលើ អាយុកាលនៃការដុះលូតលាស់របស់វា។ បើដល់អាយុហើយ យើងត្រូវពិនិត្យទៅលើលក្ខណៈដងដើមរបស់វាទៀត ដូចជាស្លឹកទី ១ ឬទី ២ ក្បែរគល់ ប្រែពីពណ៌ បៃតងទៅជាពណ៌លឿង គឺយើងអាចប្រមូលផលបាន។
- ការប្រមូលផល គឺត្រូវធ្វើឡើងដោយដៃ ចាប់ដកដើមពីក្នុងថ្នាលតែម្តង បើដីថ្នាលនោះធុសល្អ
- ម្យ៉ាងទៀត វិធីល្អបំផុតយើងត្រូវប្រើចបចក់ដែលមានធ្មេញវែងៗ គាស់វាជាមុនសិនទើបប្រមូលតាមក្រោយជាការល្អ។ ពេលវេលានៃការប្រមូល គឺត្រូវស្ងួតទឹកសន្សើម ឬគ្មានភ្លៀង ឬក៏ដីសើម ឬស្ងួតពេក។



## ២) ការតំរឹម និងសំអាត

- ការ៉ុតក្រោយពីដករួច គឺមិនត្រូវលាងទឹកទេ ពីព្រោះបើលាងវានាំឱ្យឆាប់រលួយ និងស្ពោតសាច់ផ្នែកខាងក្នុង
- ការសំអាត គឺគ្រាន់តែបេះដីណាដែលជាប់ធំពេកនៅលើមើមតែប៉ុណ្ណោះ តែមិនត្រូវឱ្យវាជ្រះពេកទេ គឺទុកវាខ្លះដើម្បីការពារសំណើម និងសំបកកុំឱ្យវារលាក
- ការតំរឹម គឺយើងកាត់តែឫសកែវ ឬឫសស្វែវែងៗ ដែលជាប់មើមរបស់វាចេញ និងកាត់ស្លឹករបស់វាដោយទុកចំងាយពីមើមប្រហែល ១-១,២ តឹក។ រួចយកវាទៅជ្រលក់ទឹកកំបោរត្រង់មុខកាត់ ដើម្បីការពារជ្រាបទឹក ឬការឆ្លងមេរោគ។





## ៣) ការជ្រើសរើស

ក្រោយពីប្រមូលផល និងកាត់ដើមឫសចេញហើយ យើងត្រូវរៀបចែកវាជា ៣ ផ្នែកគឺ ផ្នែកទី ១ ជ្រើសរើសមើមធំដាក់ម្ខុំ និងទី ២ មើមធំល្មម និងទី ៣ មើមដែលមានខ្មែង ។



## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

- ក្រោយពីសំអាត និងជ្រើសរើសរួចមក យើងអាចយកវាទៅតំរៀបក្នុងកញ្ជេដែលមានទ្រាប់ស្លឹកចេក ឬស្លឹករុក្ខជាតិផ្សេងទៀតនៅបាត និងហ៊ុំជុំវិញ
- ក្នុងការដាក់វាទៅក្នុងកញ្ជេ គួររក្សាវាឱ្យនៅមានដីខ្លះៗ នៅជាប់មើមរបស់វា បើមិនដូចនេះទេយើងយកដីខ្សាច់មករោយចន្លោះមើមដែលបានរៀបរួច ដើម្បីរក្សាសំណើម និងកាត់បន្ថយការប៉ះទង្គិច

## ១) ការប្រមូលផល

- គេអាចប្រមូលផលត្របែកបាននៅពេលសំបកផ្លែប្រែពណ៌ពីបៃតងចាស់ មកបៃតងខ្ចី
- យើងត្រូវយកកន្ត្រៃកាត់ទងដោយទុកសន្លឹកស្រស់ឱ្យនៅជាប់ផ្លែខ្លះ និងកាត់នៅពេលព្រលឹមស្រាងៗឡើងត្រជាក់ល្អ
- ពេលបេះហើយ គួរកុំដាក់ផ្លែផ្ទាល់ដី ដោយដាក់ក្នុងជាលកុំឱ្យត្រូវពន្លឺព្រះអាទិត្យ (កុំឱ្យត្រូវថ្ងៃ) គំរៀបដាក់ផ្ការយកស្លឹកឡើងលើត្រួតស៊ីគ្នា
- ក្រោយពីបេះហើយយើងដាក់ក្រោមដើមដែលមានម្លប់។





## ២) ការសំអាត

- ប្រសិនបើមានប្រឡាក់ដីជាប់ផ្លែយើងត្រូវជូតនឹងក្រណាត់ទន់ និងលាងម្តងទៀតជៀសវាងការលាងសំអាតដោយប្រើទឹក ព្រោះវាអាចឱ្យជំងឺឆាយឆ្លងពីផ្លែមួយទៅផ្លែមួយ។





## ៣) ការជ្រើសរើស

- រើសយកផ្លែណាដែលជាប់ស្លឹកស្រស់ ហើយទងវែង ផ្លែដែលមិនជាប់ស្លឹក ឬទងខ្លីត្រូវរើសចេញ
- គេរើសទុកដាក់ផ្សេងនូវផ្លែណាដែលមានសត្វស៊ី ដំបៅ រីង ឬ ជាំ។ ត្របែកជាទូទៅ យើងអាចបែងចែកជាពីរប្រភេទ ប្រភេទលេខ ១ គឺផ្លែណាដែលមានពណ៌ និងទំហំធំប្រហាក់ប្រហែលគ្នា ដោយឡែកក្រៅពីនោះផ្លែដែលល្អចាត់ទុកជាប្រភេទលេខ ២។



## ៤) របៀបវេចខ្ចប់

- មុននឹងរៀបចំផ្លែដាក់ជាលត្រូវយកស្លឹកចេកក្រាលពីក្រោម ដោយរៀបវាឱ្យមានរបៀប
- មិនត្រូវរៀបផ្លែឱ្យពេញកំពង់ហួសជាលទេ ត្រូវរៀបដាក់ឱ្យល្មម និងថ្នមៗ (ក្នុងមួយជាលប្រហែលពី ៣០ ទៅ ៤០ គីឡូក្រាម)
- ពេលរៀបមិនត្រូវចាក់ឈូសក្នុងជាលទេ។ វិធីល្អបំផុតយើងត្រូវដាក់ថ្នមៗ ដើម្បីកុំឱ្យជាំផ្លែ។ ម្យ៉ាងទៀតយើងអាចរុំក្រដាសកាសែត ឬស្រោបស្នោលើផ្លែនិមួយៗ
- ម្យ៉ាងទៀត យើងអាចដាក់ស្លឹកចេក ឬស្លឹកឈើស្រស់ ឬចំបើងតាមស្រទាប់ៗ។







## ៥) ការដឹកជញ្ជូន

- ត្រូវជ្រើសរើសយកជាលណាដែលមានទំងន់ និងទំហំប្រហាក់ប្រហែលគ្នា
- បើយើងរៀបចំមិនស្រួល ធ្វើឱ្យកំពប់ ឬជាំខូច
- ការរៀបផលិតផលដឹកចេញមិនត្រូវដាក់គរលើគ្នាទេ ត្រូវរៀបតែមួយជាន់ ឬថ្នាក់ៗទើបល្អ
- ការដឹកជញ្ជូននៅពេលថ្ងៃក្តៅត្រូវគ្របក្រណាត់ត្រជាក់ ឬសើម ដើម្បីការពារកំដៅថ្ងៃ ឬធូលី



## ៦) ការរក្សាឱ្យនៅស្រស់

- បើផ្លែនៅក្នុងជាលស្អួត ត្រូវបើកឱ្យវាត្រូវខ្យល់ កុំឱ្យបាប់ ក្នុងករណីនេះ យើងអាចកាត់កូនចេកជាកង់ៗ ដាក់នៅចន្លោះ ដែលអាចទប់ការប៉ះទង្គិច និងរក្សាសំណើមបានយូរ។
- នៅពេលដែលកំដៅថ្ងៃក្តៅ យើងត្រូវប្រោះទឹក រួចដាក់នៅកន្លែងម្លប់ តែធ្វើយ៉ាងណាឱ្យផ្លែត្របែកក្នុងកញ្ជេស្ងួតដោយខ្លួនឯង
- របៀបរក្សាទុកឱ្យបានល្អ ឬត្រជាក់ ត្រូវយកក្រណាត់ទន់មកគ្រប ឬស្លឹកចេក
- វិធីម្យ៉ាងទៀត គេអាចរុំស្លឹកចេកមួយៗ ដើម្បីឱ្យផ្លែស្រស់បានយូរ។





---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

ជា សារុធ និង វង្ស ស៊ីវឿន

# វិធីសាស្ត្រគ្រប់គ្រង
# ផ្លែត្របែក
## ក្រោយពេលប្រមូលផល




CEDAC
មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

IIRR
វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation